## មតិយោបល់របស់អង្គការសង្គមស៊ីវិល
## លើសេចក្តីព្រាងទី១០ ស្តីពី «ក្រមបរិស្ថាន និង ធនធានធម្មជាតិ
## នៃព្រះរាជាណាចក្រកម្ពុជា»

ក្នុងនាមសង្គមស៊ីវិល យើងខ្ញុំទាំងអស់គ្នា មានសេចក្តីរីករាយ និងសារទរជាខ្លាំង សម្រាប់វឌ្ឍនភាពនៃសេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ ដែលប្រកបដោយភាពពេញលេញ និងការចូលរួមដ៏ផុលផុសពីសាធារណៈជននិងអ្នកពាក់ព័ន្ធ។ វឌ្ឍនភាពនៃសេចក្តីព្រាងទី១០ នៃក្រមបរិស្ថាន និងធនធាន ធម្មជាតិ កាន់តែមានភាពល្អ ក៏ព្រោះតែភាពដឹកនាំនិងសុច្ឆន្ទៈដ៏ខ្ពង់ខ្ពស់របស់ថ្នាក់ដឹកនាំនៃក្រសួងបរិស្ថាន ជាពិសេសដោយការខិតខំនិងប្រឹងប្រែងអស់ពីសមត្ថភាពនៃក្រុមមេធាវីវិស្ណុ។

ក្នុងនាមសង្គមស៊ីវិល យើងខ្ញុំទាំងអស់គ្នា ក៏បានចូលរួមឱ្យអស់លទ្ធភាព សំដៅជំរុញឱ្យមានក្រមបរិស្ថាន និងធនធានធម្មជាតិនេះ ឆ្លើយតបពិតៗ ទៅនឹងស្ថានភាពសង្គម បរិស្ថាន នៃព្រះរាជាណាចក្រកម្ពុជាយើង។ ដំណើរការពិនិត្យលើសេចក្តីព្រាងលើកទី១០នេះ ក្រុមយើងបានធ្វើឡើងមាន៣ដំណាក់កាលធំរួមមាន៖

១. ការពិនិត្យនិងផ្តល់យោបល់តាមវិស័យ/ផ្នែក ដោយអ្នកជំនាញការឯករាជ្យ និង អង្គការសង្គមស៊ីវិល។

២. ការពិគ្រោះយោបល់ជាមួយសហគមន៍និងបណ្តាញសង្គមស៊ីវិល នៅថ្ងៃ ២១ ខែ មីនា ឆ្នាំ ២០១៨ ដោយមានការចូលរួមសរុបប្រមាណ៦៥ នាក់ (ស្ត្រី២៥នាក់)។

៣. ការពិនិត្យផ្ទៀងផ្ទាត់ បូកសរុបនិងសំយោគពីអ្នកជំនាញឯករាជ្យ និងការពិនិត្យដោយក្រុមតូចនៃបណ្តាញមុននឹងដាក់ជូនក្រុមមេធាវីវិស្ណុ និង ក្រសួងបរិស្ថាន ។

យោងតាមដំណើរការខាងលើ យើងទទួលបានលទ្ធផលជាផ្លែផ្កា ដែលជាសំណូមពរចាំបាច់មួយចំនួនសម្រាប់ក្រុមមេធាវីវិស្ណុ និងក្រសួងបរិស្ថានធ្វើការពិចារណា និងដាក់បញ្ចូលនៅក្នុងក្រមបរិស្ថាន និងធនធានធម្មជាតិ។ ទាំងនេះជាសេចក្តីសង្ខេបរួមនូវចំណុចដែល គួរពិចារណា ចំណែកមតិយោបល់លំអិតតាមមាត្រានិមួយៗនិងមានភ្ជាប់ជូនឯកសារតាមផ្នែក/វិស័យ។

មតិយោបល់និងការកែសម្រួលសង្កត់ធ្ងន់លើ (១) គោលការណ៍ ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ (FPIC) , (២) ការចូលរួមជាសាធារណៈ , (៣) ការវាយតំលៃបរិស្ថានជាយុទ្ធសាស្ត្រ, (៤)ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ, (៥) តំបន់ការពារធម្មជាតិ, (៦) ការគ្រប់គ្រងរួមគ្នា , និង (៧) មតិយោបល់ផ្សេងៗ ។ ការវាយតម្លៃជារួមចំពោះការដាក់បញ្ចូលមតិយោបល់របស់សង្គមស៊ីវិលក្នុងសេចក្តីព្រាងទី១០ គឺមានដូចខាងក្រោម៖

១. **គោលការណ៍ ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ (FPIC)៖** គឺមានការកែប្រែ និងបញ្ចូលមតិយោបល់របស់សង្គមស៊ីវិល ប្រមាណ ៦៥% ដូចមានចែងក្នុងមាត្រាទី១៧, ២៤, ២៦, ២៧, និង មាត្រាផ្សេងៗទៀតដែលពាក់ព័ន្ធ។

មតិយោបល់បន្ថែមគឺ សូមបញ្ចូល ទាំង ជនជាតិដើមភាគតិច និង ជនជាតិខ្មែរ ដែលរងផលប៉ះពាល់ផ្ទាល់ និង ប្រយោល ដើម្បីទទួលបានព័ត៌មានពីគម្រោងអភិវឌ្ឍន៍។ ចំពោះមាត្រា៣០ ស្នើឱ្យផ្តល់ពេលវេលាគ្រប់គ្រាន់ សម្រាប់សហគន៍ធ្វើការសម្រេចចិត្ត ព្រមទាំងបន្ថែមពាក់ព័ន្ធនឹងសិទ្ធិ <u>សង្គម វប្បធម៌ និងសេដ្ឋកិច្ច </u>ដើម្បីបញ្ចៀស ឬកាត់បន្ថយជាអប្បបរមានូវការគំរាមកំហែង ការបោកបញ្ឆោត ឬការបង្ខិតបង្ខំពីការផ្លាស់ប្តូរទីលំនៅថ្មី ករណីដែលតម្រូវឱ្យមានការផ្លាស់ប្តូរទីលំនៅថ្មីដោយមិនស្ម័គ្រចិត្ត ការលេចធ្លាយឧស្ម័នពុល តំបន់អសន្តិសុខ តំបន់មានគ្រោះមហន្តរាយធ្ងន់ធ្ងរ ជាដើម។ ចំពោះមាត្រាមួយចំនួនដែលត្រូវបានដកចេញនិងកែសម្រួល សង្គមស៊ីវិលយើងខ្ញុំស្នើឱ្យមានការពិនិត្យបន្ថែមលើមតិយោបល់ដែលមានក្នុងសេចក្តីព្រាងទី ៩.១ និងមតិយោបល់បន្ថែមលើសេចក្តីព្រាងទី១០នេះ។

២. **ការចូលរួមជាសាធារណៈ ៖** មានការកែប្រែ និងបញ្ចូលមតិយោបល់របស់សង្គមស៊ីវិល ប្រមា ៦០% ដោយបង្ហាញពីការផ្តល់ឱកាសដល់សាធារណៈជន និង អ្នកពាក់ព័ន្ធផ្សេងៗចូលរួមផ្តល់តិយោបល់លើគម្រោងអភិវឌ្ឍនានា។ មតិយោបល់បន្ថែមសំខាន់នោះគឺ ចំពោះការចូលរួមក្នុងកិច្ចដំណើរការរបស់គម្រោងអភិវឌ្ឍន៍នីមួយៗ គឺតម្រូវឱ្យធ្វើរបាយការណ៍ជាលាយល័ក្ខអក្សរផ្ញើរទៅជូនអាជ្ញាធរមូលដ្ឋានដើម្បីធានាពីការចូលរួមដឹងលឺពីផលប៉ះពាល់ ក៏ដូចជាផលចំណេញដែលបានពីគម្រោង ជាពិសេស គឺត្រូវធានាថាមានព័ត៌មានគ្រប់ជ្រុងជ្រោយ និងមានការផ្តល់ឱកាសឱ្យសមាជិកសហគមន៍ ដែលទទួលរងផលប៉ះពាល់ដោយផ្ទាល់ក្តី ឬដោយប្រយោលក្តីបានចូលរួមពេញលេញក្នុងការសម្តែង មតិ និងផ្តល់មតិយោបល់ប្រកបដោយតម្លាភាពនិងគណនេយ្យភាព។ ក្នុង មាត្រាទី ២៣ ស្នើឱ្យ បញ្ចូល ចំណុចមួយទៀតគឺ <u>រាល់គម្រោងអភិវឌ្ឍ និងផែនការវិនិយោគបាននិងកំពុងអនុវត្ត ដោយពុំមានការចូល រួមជាសាធារណៈ ឬមិនបានពេញលេញត្រូវផ្អាកជាបណ្តោះអាសន្ន និង ត្រូវរៀបចំផែនការនិងអនុវត្ត ការចូលរួមជាសាធារណឱ្យបានពេញលេញក្នុងរយៈពេល៦០ថ្ងៃ បន្ទាប់ពីក្រមនេះចូលជាធរមាន។</u>

៣. **ការវាយតំលៃបរិស្ថានជាយុទ្ធសាស្ត្រ ៖** គឺមានការកែប្រែ និងបញ្ចូលមតិយោបល់របស់សង្គមស៊ីវិល ប្រមាណ ៦០%។ មតិយោបល់សំខាន់ក្នុងប្រធានបទនេះដែលត្រូវពិចារណា គឺ ត្រូវធានាថាមានការចូលរួមពីសាធារណៈជន និងក្រុមប្រឹក្សាឯករាជ្យ និងគ្រប់ភាគីពាក់ព័ន្ធក្នុងការវាយតម្លៃបរិស្ថានជា យុទ្ធសាស្ត្រ ហើយ <u>ការប្រែប្រួលអាកាសធាតុ ការគិតគូរពី យេនឌ័រ ស្ត្រី កុមារ ជនពិការចាស់ជរា គួរ ត្រូវបានដាក់បញ្ចូលធ្វើការវិភាគក្នុងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ</u>។ ចំណុចបន្ថែមក្នុងមាត្រា៦៦ គឺ ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវមានភារៈកិច្ច និងទទួលខុសត្រូវចំពោះការ <u>បង្កើតគណៈកម្មការជំនាញត្រួតពិនិត្យតាមការចាំបាច់</u> ។

៤. **ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ៖** គឺមានការកែប្រែ និងបញ្ចូលមតិយោបល់របស់សង្គមស៊ីវិលប្រមាណ ៧៣%។ ទាក់ទងនឹង **ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ** ច្បាប់គ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ គោលការណ៍សេនដាយ (Sendai

Framework) គួរដាក់បញ្ចូលបន្ថែមក្នុងក្រមទាំងនេះ ជាពិសេសគឺ ការធានាថាមានកញ្ចប់ថវិកាសម្រាប់ការអនុវត្ត CCA & DRR ដែលជាការវិភាជន៍ថវិការបស់ជាតិដាច់ដោយឡែក ដើម្បីប្រើប្រាស់លើការងារគ្រប់គ្រង និង ការឆ្លើយតបហានិភ័យគ្រោះមហន្តរាយ ដោយមិនចាំបាច់ត្រូវរង់ចាំជំនួយពីខាងក្រៅដើម្បីរួមបញ្ចូលជាមួយថវិការអភិវឌ្ឍន៍ឃុំ/សង្កាត់។

៥. **តំបន់ការពារធម្មជាតិ ៖** គឺមានការកែប្រែ និងបញ្ចូលមតិយោបល់របស់សង្គមស៊ីវិល តិចជាង ៥០%។ ទោះយ៉ាងណាក៏ដោយ ក្រុមពិភាក្សាបានពិនិត្យឃើញមានការកែលម្អចំពោះមាត្រាមួយចំនួនដូចជា មាត្រា៣៣៧ ស្តីពីការគ្រប់គ្រងព្រៃឈើ គឺបានបញ្ជាក់បន្ថែមពីដែនសមត្ថកិច្ចគ្រប់គ្រងរបស់ស្ថាប័នទទួលបន្ទុកព្រៃឈើ, មាត្រា៣៦៨ ស្តីពីសកម្មភាពដែលតម្រូវឱ្យមានលិខិតអនុញ្ញាត, មាត្រា ៣៧២ និង ៣៧៣ គឺបកស្រាយបានក្បោះក្បាយ។ យើងខ្ញុំសូមស្នើ សុំឱ្យមានការពិភាក្សា និង ពិនិត្យលើមតិយោបល់លំអិតរបស់សង្គមស៊ីវិលបន្ថែម ជាពិសេសគឺ អង្គការ WWF និង RECOFTC ដើម្បីបញ្ចូលនៅកន្លែងខ្វះចន្លោះនៃសេចក្តីព្រាងទី១០។

៦. **ការគ្រប់គ្រងរួមគ្នា ៖** គឺមានការកែប្រែ និងបញ្ចូលមតិយោបល់របស់សង្គមស៊ីវិលតិចជាង ៥០%។ ដោយសង្កេតឃើញថា រវាងសេចក្តីព្រាងទី៩.១ និង ទី១០ គឺមានភាពខុសគ្នាច្រើន និង មានការដកចេញមាត្រាមួយចំនួនធំ។ ចំនុចសំខាន់គឺ មាត្រា ៣១៦, មាត្រា៣១៧, មាត្រា ៣២០, មាត្រា ៣២៦, និងផ្នែកទាក់ទងនៃមាត្រាទាំងនេះទៅនឹង មាត្រាទី ១០៦៣ នៃគន្ថី ១២។ ក្នុងមាត្រា ៣១៧ មាត្រាទ ៣២០ និង មាត្រា ៣២៦ គប្បីធ្វើការកែលំអបន្ថែមចំពោះស្ថាប័នមានសមត្ថកិច្ចរួមបញ្ចូល សហគមន៍ និង អង្គការសង្គមស៊ីវិល ដែលបានចូលរួមគ្រប់គ្រងធនធានធម្មជាតិ។ មាត្រាទី ១០៦៣ អំពីអវសានប្បញ្ញត្តិ ចំពោះការធ្វើនិរាករណ៍រាល់បទប្បញ្ញតិទាំងឡាយណាដែលផ្ទុយពីក្រមនេះ គួរ កែសម្រួល ទៅពាក្យ <u>ការធ្វើវិសោធនកម្ម</u> ។

៧. **មតិយោបល់ផ្សេងៗបន្ថែម ៖**

- ជាទូទៅនៅមានកំហុសអក្ខរាវិរុទ្ធ ឃ្លាឃ្លោង ជាពិសេសសូមពិនិត្យកែសម្រួលឃ្លា ល្បះឱ្យមានលក្ខណៈនិងបែបបទជាភាសាខ្មែរផ្លូវការ(វិធានច្បាប់) ជាជាងប្រើប្រាស់ទម្រង់អង់គ្លេស បែបអសកម្មលើប្រធានបទ។
- ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ ច្បាប់គ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ គោលការណ៍សេនដាយ (Sendai Framework) គួរដាក់បញ្ចូលបន្ថែមក្នុងក្រមទាំងនេះ ជាពិសេសគឺ ការធានាថាមានកញ្ចប់ថវិកា សម្រាប់ការអនុវត្ត CCA & DRR ដែលជាការវិភាជន៍ថវិការបស់ជាតិដាច់ដោយឡែក ដើម្បីប្រើប្រាស់លើការងារគ្រប់គ្រង និង ការឆ្លើយតបហានិភ័យគ្រោះមហន្តរាយ ដោយមិនចាំបាច់ត្រូវរង់ចាំជំនួយពីខាងក្រៅដើម្បីរួមបញ្ចូលជាមួយថវិការអភិវឌ្ឍន៍ឃុំ/សង្កាត់។
- ចំពោះការចូលរួមជាសាធារណៈ គឺតម្រូវឱ្យមានការចូលរួមទាំងសហគមន៍ជនជាតិដើមភាគតិច និង សហគមន៍រងផលប៉ះពាល់ដោយផ្ទាល់ និង ដោយប្រយោល ហើយមានការចូលរួម

គ្រប់ដំណាក់កាលនៃការអនុវត្តគម្រោង  រួមមាន ១. ដំណាក់កាលសិក្សាស្រាវជ្រាវបឋម   ២. ដំណាក់កាលរៀបចំគម្រោង និង ៣ ដំណាក់កាលអនុវត្ត និង ៤. ដំណាក់កាលបញ្ចប់គម្រោង

- ចំពោះការគ្រប់គ្រងរួមគ្នាលើធនធានធម្មជាតិ គឺត្រូវធ្វើការកែលម្អ ទាក់ទងនឹងការកំណត់វិសាលភាព និង ដែនសមត្ថកិច្ចនៃស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធក្នុងការធ្វើការរួមគ្នា ដើម្បីជៀសវាងការជាន់តួនាទីរវាងស្ថានប័នមួយទៅស្ថាប័នមួយទៀត។ ជាងនេះទៅទៀត ត្រូវផ្តល់សិទ្ធិឱ្យសហគមន៍ចូលរួមជាមួយអង្គការសង្គមស៊ីវិល និង ស្ថាប័នរដ្ឋាភិបាលដើម្បីធ្វើការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព។
- សូមរក្សាមាត្រា២០ ចាស់ ក្នុងសេចក្តីព្រាងទី ៩.១) ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់នឹងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ) តាមសំណូមពរកំណែប្រែថ្មី/ក្នុងមាត្រា២០ នៃពង្រាងទី ៩១.។
- មាត្រា៣៥.  ព័ត៌មានពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ស្នើពិចារណាដាក់បញ្ចូល *លក្ខខណ្ឌការងារសម្រាប់កិច្ចដំណើរការការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន*
- មាត្រា៦៣នីតិវិធីស្នើសុំព័ត៌មាន .  លើចំណុច៖ (i) ក្រសួង ស្ថាប័នពាក់ព័ន្ធអាចរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីស្នើសុំព័ត៌មាន និង (ii) នីតិវិធីស្នើសុំព័ត៌មាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ។ ចំណុចពិចារណា៖ តើនីតិវិធីនេះ គួរតែមានកំណត់ពេលវេលានៃការឆ្លើយតបដែរឬទេ ?ហើយតើនីតិវិធីនេះ សមស្របសម្រាប់សហគមន៍មូលដ្ឋានដែរឬទេ) គោលការណ៍នៃការចូលរួមជាសាធារណៈ?
- គន្ទីទី២ មាតិកាទី២ ជពូកទី៣៖ កិច្ចដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មាត្រា ១០៩ ដល់មាត្រា១៣៥ - តាមមតិយោបល់ លើសេចក្តីព្រាងទី៩.១ ស្នើសុំឱ្យមានការចូលរួមជាសាធារណៈ នៅក្នុងគ្រប់ដំណាក់កាលនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយឡែកនៅក្នុងជំពូកទី៣ នេះមិនមានការបញ្ជាក់ពីការចូលរួមជាសាធារណៈ ជំពូកទី៥ ការចូលរួមជា) ។ ការចូលរួមជាសាធារណៈ មានតែនៅក្នុងដំណាក់កាល(សាធារណៈ ត្រូវបានលុបចោល (មាត្រា១១៥) កំណត់វិសាលភាពដំណាក់កាលការវាយតម្លៃលើរបាយការណ៍ មាត្រា) (១២៣តែប៉ុណ្ណោះ

- ស្នើសុំឱ្យមានការពិចារណាបន្ថែមក្នុងពង្រាងបន្ទាប់ទាក់ទង នឹងការចាត់វិធានការ និងយន្តការនានា ក្នុងការគ្រប់គ្រង និង ការអនុវត្ត ការប្រើប្រាស់សារធាតុគីមីកសិកម្មដែលបំពុលដល់ដី និង ទឹក។

(ចំពោះមតិយោបល់លំអិត សូមពិនិត្យក្នុងតារាងមតិយោបល់របស់អង្គការសង្គមស៊ីវិល ដែលមានភ្ជាប់ជូនជាមួយ)

## មតិយោបល់របស់អង្គការសង្គមស៊ីវិល

## លើសេចក្តីព្រាងទី១0នៃ ក្រមបរិស្ថាន និង ធនធានធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា

## ប្រធានបទ៖ ការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាន

| លរ<br>NO | គន្លឹ/មាតិកា/ជំពូក លើពង្រាងទី៩.១<br>**Book/Title**<br>**(Copy and Paste from Environment Code)** | មតិយោបល់របស់សង្គមស៊ីវិល លើពង្រាងទី ៩.១ | សំណូមពរ/កំណែប្រែថ្មី លើពង្រាងទី ១០<br>( CSO Suggestions ) |
|---|---|---|---|
| ១ | **មាត្រា៥** ._ គោលការណ៍នៃការចូលរួមជាសាធារណៈ<br>បុគ្គលទាំងឡាយណា ដែលអាចទទួលរងនូវផលប៉ះពាល់ដោយផ្ទាល់ ឬប្រយោល ដោយសារការសម្រេចចិត្តណាមួយទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ មានសិទ្ធិចូលរួមផ្តល់មតិយោបល់ទាន់ពេលវេលា និងបន្ទាប់ពីទទួលបានព័ត៌មាន មុនពេលដែលការសម្រេចចិត្តនោះត្រូវបានធ្វើឡើង តាមរយៈដំណើរការមួយប្រកបដោយតម្លាភាព ការចូលរួម និងគណនេយ្យភាព ។ | **មាត្រា៥** ._ គោលការណ៍នៃការចូលរួមជាសាធារណៈ<br><br>បុគ្គលទាំងឡាយណា ដែលអាចទទួលរងនូវផលប៉ះពាល់ដោយផ្ទាល់ ប្រយោល ឬចាប់អារម្មណ៍ក្នុងការសម្រេចចិត្តណាមួយទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ មានសិទ្ធិចូលរួម ផ្តល់មតិយោបល់ទាន់ពេលវេលា និងបន្ទាប់ពីទទួលបានព័ត៌មាន មុនពេលដែលការសម្រេចចិត្តនោះត្រូវបានធ្វើឡើង តាមរយៈដំណើរការមួយ ប្រកបដោយតម្លាភាព ការចូលរួម និងគណនេយ្យភាព។ | មិនបានទទួលយកការកែសម្រួល<br>ស្នើឱ្យពិនិត្យបន្ថែមមតិយោបល់របស់សង្គមស៊ីវិល លើពង្រាងទី ៩.១<br><br>គោលការណ៍នៃការចូលរួមជាសាធារណៈ<br>ស្ថាប័នសាធារណៈត្រូវផ្តល់ព័ត៌មានឲ្យបានគ្រប់ជ្រុងជ្រោយ និងផ្តល់ឱកាសឲ្យសមាជិកសហគមន៍ដែលទទួលរងផលប៉ះពាល់ទោះបីជាដោយផ្ទាល់ក្តី ឬដោយប្រយោលក្តីបានចូលរួមពេញលេញក្នុងការសម្តែងមតិ និងផ្តល់មតិយោបល់ប្រកបដោយតម្លាភាពនិងគណនេយ្យភាព។<br><br>បុគ្គលទាំងឡាយណា ដែលអាចទទួលរងនូវផលប៉ះពាល់ដោយផ្ទាល់ ប្រយោល ឬចាប់អារម្មណ៍ក្នុងការសម្រេចចិត្តណាមួយទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ មានសិទ្ធិចូលរួមពេញលេញក្នុងការផ្តល់មតិយោបល់ទាន់ពេល |

<table>
<tr><td></td><td></td><td></td><td>វេលា និងបន្ទាប់ពីទទួលបានព័ត៌មាន មុនពេលដែលការសម្រេចចិត្តនោះត្រូវបានធ្វើឡើង តាមរយៈដំណើរការមួយប្រកបដោយតម្លាភាព ការចូលរួម និងគណនេយ្យភាព។</td></tr>
<tr><td>២</td><td colspan="3">មតិយោបល់ថ្មី<br><br>មាត្រាទី៧ គោលការណ៍នៃការទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព<br>បុគ្គលគ្រប់រូប មានសិទ្ធិទទួលបានដំណោះស្រាយផ្នែករដ្ឋបាល និងផ្នែកតុលាការ ឬក៏មធ្យោបាយសមស្របដទៃទៀត ដែលពាក់ព័ន្ធទៅនឹងវិវាទបរិស្ថាន និងធនធានធម្មជាតិ ប្រកបដោយ<u>យុត្តិធម៌</u>និងប្រសិទ្ធភាព ។<br>យន្តការដោះស្រាយវិវាទ ប្រកបដោយប្រសិទ្ធភាព និងមិនលម្អៀង ត្រូវរៀបចំឡើង ដើម្បីលើកកម្ពស់ការអនុវត្តច្បាប់និង ផ្តន្ទាទោសចំពោះបុគ្គលគ្រប់រូប ដែលបង្កការខូចខាតដល់បរិស្ថាននិងធនធានធម្មជាតិ។<br><br>មាត្រា៨ ._ គោលការណ៍<u>អ្នកបង្កហេតុឲ្យមានការខូចខាតបរិស្ថាន និងធនធានធម្មជាតិ</u><br>~~អ្នកបំពុលត្រូវទទួលខុសត្រូវទាំងស្រុងលើតម្លៃនៃការបំពុល~~<br>បុគ្គលគ្រប់រូប ដែលបានបង្កឲ្យមានការខូចខាតចំពោះបរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលបន្ទុកបង់ថ្លៃចំណាយ<u>ទាំងស្រុង</u>លើការជួសជុល និងវិធានការទប់ស្កាត់ បញ្ចៀស និងកាត់បន្ថយការខូចខាតបរិស្ថាននិងធនធានធម្មជាតិ។<br>(ការបកតាមភាសាអង់គ្លេសត្រឹមត្រូវ តែអត្ថន័យជាភាសាខ្មែរមិនត្រឹមត្រូវ)<br><br>មាត្រា៩ ._ គោលការណ៍<u>បង្ការនិង</u>នៃការប្រុងប្រយ័ត្នជាមុន<br>~~ក្នុងករណីដែលមានការគំរាមកំហែង ឬ ការខូចខាតយ៉ាងធ្ងន់ធ្ងរចំពោះបរិស្ថាន ដែលមិនអាចជួសជុលឡើងវិញបាន កង្វះខាតភាពប្រាកដប្រជាផ្នែកវិទ្យាសាស្ត្រ មិនត្រូវយកមកធ្វើជាមូលហេតុ ក្នុងការពន្យារពេលនៃការចាត់វិធានការ ដើម្បីទប់ស្កាត់ការខូចខាតដល់បរិស្ថានបានឡើយ។~~</td></tr>
</table>

| | | | |
|---|---|---|---|
| | <u>ត្រូវមានវិធានបង្ការនិងប្រុងប្រយ័ត្នជាមុន  រាល់សកម្មភាពទាំងឡាយ ដែលមិនមានភាពច្បាស់លាស់ឬកង្វះខាតពត៌មានវិទ្យាសាស្ត្រ ពីការប៉ះពាល់បរិស្ថាន ជាពិសេសការគំរាមកំហែងឬការខូចខាតធ្ងន់ធ្ងរចំពោះបរិស្ថាន ដែលមិនអាចធ្វើឲ្យត្រឡប់ដូចភាពដើមបាន ឬបាត់បង់វត្តមានជាអចិន្ត្រៃយ៍។</u><br>( ពិបាកយល់ណាស់ឃ្លានេះ គួរកែសម្រួល ដោយសូមកែសម្រួលទាំងស្រុង )<br><br>**មាត្រា១២** ._គោលការណ៍នៃការធ្វើសេចក្តីសម្រេចដោយផ្អែកលើភស្តុតាង<br>ចំណុចស្នើឱ្យពិចារណា៖ <u>ការធ្វើការសម្រេចចិត្តទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ ត្រូវមានមានតម្លាភាព និងផ្អែកលើភស្តុតាងជាមូលដ្ឋាន ដោយប្រើប្រាស់ព័ត៌មានដ៏ប្រសើរបំផុតដែលអាចស្វែងរកបាន ។ ព័ត៌មានទាំងនោះ អាចមានលក្ខណៈវិទ្យាសាស្ត្រ  ឬបច្ចេកទេស និងអាចជាទិន្នន័យដែលប្រមូលបានមកពីសហគមន៍ និងចំណេះដឹងរបស់ជនជាតិដើមម្ចាស់ស្រុកផងដែរ ។</u><br>( សំណូមពរសូមយកតាមមាត្រាចាស់នៃកំណែ៩.១ វិញ។)<br><br>**មាត្រាទី ១៣ នៃពង្រាងទី១០**<br>**មាត្រា១៣ ._ គោលការណ៍សមភាពយេនឌ័រក្នុងការធ្វើសម្រេចពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ**<br>សមភាពយេនឌ័រ និងការចូលរួមរបស់ស្ត្រីទាក់ទងនឹងការធ្វើសេចក្តីសម្រេចពាក់ព័ន្ធនឹង បរិស្ថាន និងធនធានធម្មជាតិ ត្រូវទទួលបានការលើកកម្ពស់ និងការលើកទឹកចិត្ត ។<br><u>(មិនទាន់ពេញលេញសូមបន្ថែមអត្ថន័យ)</u> | | |
| ៣ | **មាត្រា១៨** ._ គោលការណ៍ ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ សម្រាប់សហគមន៍ជនជាតិដើមភាគតិច<br>សកម្មភាព ឬ គម្រោងដែលស្នើសុំ ដែលអាចប៉ះពាល់ដល់ដីធ្លី ឬធនធានដទៃទៀត ជា ពិសេស ដែលទាក់ទងទៅនឹងការអភិវឌ្ឍ ការប្រើប្រាស់ | **មាត្រា១៨** ._ គោលការណ៍ ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ សម្រាប់សហគមន៍ជនជាតិដើមភាគតិច<br>សកម្មភាព ឬ គម្រោងដែលស្នើសុំ ដែលអាចប៉ះពាល់ដល់ដីធ្លី ឬធនធានដទៃ | ក្នុង មាត្រាទី ១៧ និង មាត្រាទី២៦ នៃពង្រាងទី១០<br><br>ស្នើឱ្យពិនិត្យបន្ថែមមតិយោបល់របស់សង្គមស៊ីវិល លើពង្រាងទី ៩.១<br>ស្នើបន្ថែមដូចខាងក្រោម៖<br>**មាត្រា២៦** ._ ការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ |

| | | | |
|---|---|---|---|
| | និងការធ្វើអាជីវកម្មលើធនធានធម្មជាតិ ត្រូវទទួលនូវការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយរបស់ជនជាតិដើមភាគតិច ។ | ទៀត ជាពិសេស ដែលទាក់ទងទៅនឹងការអភិវឌ្ឍ ការប្រើប្រាស់ និងការធ្វើអាជីវកម្មលើធនធានធម្មជាតិ ត្រូវទទួលនូវការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ របស់ជនជាតិដើមភាគតិច <u>នៅគ្រប់ដំណាក់កាលនៃគម្រោងដែលស្នើរឡើង រួមមាន ១) ដំណាក់កាលសិក្សាស្រាវជ្រាវបឋម ២) ដំណាក់កាលរៀបចំគម្រោង និង ៣) ដំណាក់កាលអនុវត្តគម្រោង និង ៤) ដំណាក់កាលបញ្ចប់គម្រោង។</u> | ក្រសួង ស្ថាប័នមានសមត្ថកិច្ច មិនត្រូវឯកភាពលើគម្រោងស្នើសុំ ដែលអាចប៉ះពាល់ដោយផ្ទាល់ចំពោះ ដីធ្លី និងធនធានរបស់<u>សហគមន៍មូលដ្ឋាន និង</u>ជនជាតិដើមភាគតិច ដោយគ្មានការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយបានឡើយ ។ ការយល់ព្រមរបស់<u>សហគមន៍មូលដ្ឋាន និង</u>ជនជាតិដើមភាគតិច ត្រូវធ្វើឡើងដោយមតិភាគច្រើនដាច់ខាតនៃ<u>សហគមន៍មូលដ្ឋាន និង</u>ជនជាតិដើមភាគតិច ដែលអាចទទួលរងផលប៉ះពាល់ពីគម្រោងស្នើសុំ ឬការធ្វើសេចក្ដីសម្រេចនេះ ។ |
| ៤ | **មាត្រា២១** ._ សិទ្ធិក្នុងការចូលរួមជាសាធារណៈ<br>រូបវន្តបុគ្គលគ្រប់រូប មានសិទ្ធិក្នុងការចូលរួមជាសាធារណៈតាមរយៈដូចខាងក្រោម ។ រូបវន្តបុគ្គលគ្រប់រូប អាចអនុវត្តសិទ្ធិរបស់ខ្លួន ក្នុងការចូលរួមសាធារណៈ តាមរយៈ ៖<br>១- រាយការណ៍ទៅកាន់អាជ្ញាធរពាក់ព័ន្ធ និងផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាព ឬការសម្រេចចិត្តណាមួយ ដែលអាចនឹងមានផលប៉ះពាល់ទៅលើបរិស្ថាន និងធនធានធម្មជាតិ ។<br>២- លើកឡើងនូវសំណួរ និងស្នើឲ្យមានការបញ្ជាក់ឲ្យច្បាស់អំពីការ | **មាត្រា២១** ._ សិទ្ធិក្នុងការចូលរួមជាសាធារណៈ<br>រូបវន្តបុគ្គលគ្រប់រូប មានសិទ្ធិក្នុងការចូលរួមជាសាធារណៈតាមរយៈដូចខាងក្រោម ។<br>រូបវន្តបុគ្គលគ្រប់រូប អាចអនុវត្តសិទ្ធិរបស់ខ្លួន ក្នុងការចូលរួមសាធារណៈ តាមរយៈ ៖<br>១- រាយការណ៍ទៅកាន់អាជ្ញាធរពាក់ព័ន្ធដោយ<u>ផ្ទាល់មាត់ និង ជាលាយលក្ខអក្សរ</u> ដើម្បីធ្វើការផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាព ឬការសម្រេចចិត្តណាមួយ ដែលអាចនឹងមាន | មិនបានទទួលយកការកែសម្រួល<br><br>ស្នើឱ្យពិនិត្យបន្ថែមមតិយោបល់របស់សង្គមស៊ីវិល លើពង្រាងទី៩.១<br>ស្នើកែប្រែដូចខាងក្រោម៖<br>**មាត្រា២១ ._ សិទ្ធិក្នុងការចូលរួមជាសាធារណៈ**<br>បុគ្គលគ្រប់រូប មានសិទ្ធិចូលរួមជាសាធារណៈ និងអាចអនុវត្តសិទ្ធិរបស់ខ្លួន ដូចខាងក្រោម ៖<br>១- រាយការណ៍<u>*ផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ*</u> ទៅកាន់អាជ្ញាធរពាក់ព័ន្ធ និងផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាព ឬការធ្វើសេចក្ដីសម្រេចណាមួយ ដែលអាច |

| | | | |
|---|---|---|---|
| | ជំទាស់ និងការជួបប្រជុំ ដើម្បីពិភាក្សា ដោយគ្មានអំពើហិង្សា អំពីសកម្មភាព ឬ សេចក្តីសម្រេចណាមួយ ដែលអាចប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិ និង<br>៣- ដាក់ពាក្យបណ្តឹង ឬណ្តឹងជំទាស់ទៅនឹងសកម្មភាព ឬសេចក្តីសម្រេច ទៅកាន់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមការងារដោះស្រាយវិវាទបរិស្ថាន ឬ តុលាការមានសមត្ថកិច្ច ស្របទៅតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងគន្ថីទី៩នៃក្រមនេះ ។ | ផលប៉ះពាល់ទៅលើបរិស្ថាន និងធនធានធម្មជាតិ ។<br><br>២- លើកឡើងនូវសំណួរ ស្នើឱ្យមានការបកស្រាយ ធ្វើការតវ៉ា និងចូលរួមពិភាក្សា អំពីសកម្មភាព ឬ សេចក្តីសម្រេចណាមួយ ដែលអាចបង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិ ។<br>*ទទួលបានព័ត៌មាន និងមានការចូលរួមទាន់ពេលវេលា ក្នុងការពិភាក្សា និងផ្តល់មតិយោបល់ សម្រាប់សេចក្តីសម្រេចណាមួយ ដែលអាចបង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិ។*<br>៣- ដាក់ពាក្យបណ្តឹង ឬប្តឹងតវ៉ានឹងសកម្មភាព ឬសេចក្តីសម្រេច ស្របតាមយន្តការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ដូចមានចែងក្នុង គន្ថីទី៩នៃក្រមនេះ ។ | នឹងមានផលប៉ះពាល់ទៅលើបរិស្ថាន និងធនធានធម្មជាតិ ។<br>២- លើកឡើងនូវសំណួរ ស្នើឱ្យមានការបកស្រាយ ធ្វើការតវ៉ា និងចូលរួមពិភាក្សា អំពីសកម្មភាព ឬ សេចក្តីសម្រេចណាមួយ ដែលអាចបង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិ ។<br>*ទទួលបានព័ត៌មាន និងមានការចូលរួមទាន់ពេលវេលា ក្នុងការពិភាក្សា និងផ្តល់មតិយោបល់ សម្រាប់សេចក្តីសម្រេចណាមួយដែលអាចបង្កឱ្យមានផលប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិ។*<br>៣- ដាក់ពាក្យបណ្តឹង ឬប្តឹងតវ៉ានឹងសកម្មភាព ឬសេចក្តីសម្រេច ស្របតាមយន្តការដោះស្រាយវិវាទបរិស្ថាន និងធនធានធម្មជាតិ ដូចមានចែងក្នុង គន្ថីទី៩នៃក្រមនេះ ។ |
| | **មតិយោបល់ថ្មី**<br><br>**មាត្រា២២** ._ សិទ្ធិទទួលបានការការពារចំពោះការគំរាមកំហែង និងការសងសឹក | | |

| | | | |
|---|---|---|---|
| | បុគ្គលគ្រប់រូបដែលអនុវត្តសិទ្ធិក្នុងការចូលរួមជាសាធារណៈដូចមានចែងក្នុងមាត្រា២១ខាងលើ ត្រូវរួចផុតពីការគំរាមកំហែង និងការសងសឹកតាមគ្រប់មធ្យោបាយនានា ។ រាល់សកម្មភាពក្នុងការចូលរួមជាសាធារណៈដែលស្របតាមមាតិកានេះ មិនត្រូវទទួលរងការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ឬប្រឈមនឹងបណ្តឹងទាមទារផ្នែករដ្ឋប្បវេណីណាមួយឡើយ ។<br>~~សិទ្ធិក្នុងការទទួលបានការការពារពីការគំរាមកំហែង ឬ ការសងសឹក ចំពោះការចូលរួមជាសាធារណៈ មិនត្រូវរួចផុតពីការចោទប្រកាន់ពីបទព្រហ្មទណ្ឌ ឬបណ្តឹងទាមទារផ្នែករដ្ឋប្បវេណីឡើយ ក្នុងករណីដែលបុគ្គលដែលបានចូលរួមជាសាធារណៈប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយដូចមានចែងក្នុងក្រមនេះ ឬក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឬបង្កឲ្យមានអំពើអនីត្យានុកូលណាមួយ ដូចមានចែងនៅក្នុងក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ។~~<br><br>(សំណូមពរលុប ឃ្លាខាងលើនេះចោល ពីព្រោះនិយាយទៅមក ឲ្យសិទ្ធិផងនិងគាប/បិទផង(ដូចមិនត្រឹមត្រូវ)។ ប្រសិនបើបញ្ហាជាបទល្មើសព្រហ្មទណ្ឌ ដូចនេះវាជាការកំណត់នៅក្នុងក្រមព្រហ្មទណ្ឌរួចទៅ។ មិនចាំបាច់លើកទៀតទេ ហាក់ដូចជាស្មួននិងមិនមានសុគតភាព។) | | |
| ៥ | **មាត្រា២៤** ._ លក្ខខណ្ឌតម្រូវសម្រាប់ការចូលរួមជាសាធារណៈ<br>មុននឹងធ្វើការសម្រេចចិត្ត ឬឯកភាពណាមួយ ដែលស្ថិតក្រោមបទប្បញ្ញត្តិនៃក្រមនេះ ក្រសួង ស្ថាប័នដែលពាក់ព័ន្ធត្រូវយល់ស្របថាការចូលរួមជាសាធារណៈដែលពេញលេញ បានកើតមានឡើង ដូចខាងក្រោម៖<br>ក- ព័ត៌មានដែលពាក់ព័ន្ធទាំងអស់ត្រូវបានលើកបង្ហាញតាមមធ្យោបាយសមស្រប ដោយស្របទៅនឹងតម្រូវការរបស់អ្នកពាក់ព័ន្ធ ។ | **មាត្រា២៤** ._ លក្ខខណ្ឌតម្រូវសម្រាប់ការចូលរួមជាសាធារណៈ<br>មុននឹងធ្វើការសម្រេចចិត្ត ឬឯកភាពណាមួយ ដែលស្ថិតក្រោមបទប្បញ្ញត្តិនៃក្រមនេះ ក្រសួង ស្ថាប័នដែលពាក់ព័ន្ធត្រូវយល់ស្របថាការចូលរួមជាសាធារណៈដែលពេញលេញ បានកើតមានឡើង ដូចខាងក្រោម៖<br>ក- ព័ត៌មានដែលពាក់ព័ន្ធទាំងអស់ត្រូវបានលើកបង្ហាញតាមមធ្យោបាយសមស្រប ដោយស្របទៅនឹងតម្រូវការរបស់អ្នកពាក់ព័ន្ធ ។ | បានទទួលយកការកែសម្រួលក្នុងមាត្រាទី ២៣<br>ប៉ុន្តែមិន ទាន់ដាក់បញ្ចូលយោបល់ លើសេចក្តីព្រាងទី៩.១ សម្រាប់ការធ្វើប្រតិសកម្មចំពោះគម្រោងអភិវឌ្ឍ និងផែនការវិនិយោគបាននិងកំពុងអនុវត្ត<br><br>**មាត្រា២៣** ._ លក្ខខណ្ឌតម្រូវសម្រាប់ការចូលរួមជាសាធារណៈ<br>មុននឹងធ្វើសេចក្តីសម្រេច ឬឯកភាពលើបញ្ហាណាមួយពាក់ព័ន្ធនឹងក្រមនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងម្ចាស់គម្រោងទាំងអស់ ត្រូវបំពេញតាមលក្ខខណ្ឌតម្រូវសម្រាប់ការចូលរួមជាសាធារណៈ ដូចខាងក្រោម៖ |

| | | | |
|---|---|---|---|
| | ខ- អ្នកពាក់ព័ន្ធមានពេលវេលា និងឱកាសគ្រប់គ្រាន់ក្នុងការពិចារណាទៅលើព័ត៌មានពាក់ព័ន្ធនេះ ។<br>គ- អ្នកពាក់ព័ន្ធអាចដាក់ជូនមតិយោបល់ ធាតុចូល និងសំណូមពរនានាទៅកាន់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ មុននឹង ការសម្រេចចិត្ត ឬការឯកភាព ត្រូវបានឡើង ។<br>ឃ- ក្រសួង ស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធបានដោះស្រាយទៅលើមតិយោបល់ ធាតុចូល និងសំណូមពរនានានេះដែលធ្វើឡើងដោយអ្នកពាក់ព័ន្ធ ។<br>ង- ការចូលរួមជាសាធារណៈត្រូវមានលក្ខណៈសមស្រប និងដើម្បីធ្វើការសម្រេចចិត្ត ឬការផ្តល់ការឯកភាពណាមួយ ។ | ខ- អ្នកពាក់ព័ន្ធមានពេលវេលា និងឱកាសគ្រប់គ្រាន់ក្នុងការពិចារណាទៅលើព័ត៌មានពាក់ព័ន្ធនេះ ។<br>គ- អ្នកពាក់ព័ន្ធអាចដាក់ជូនមតិយោបល់ ធាតុចូល និងសំណូមពរនានា ទៅកាន់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ មុននឹង ការសម្រេចចិត្ត ឬការឯកភាព ត្រូវបានឡើង ។<br>ឃ- ក្រសួង ស្ថាប័នរាជរដ្ឋាភិបាលដែលពាក់ព័ន្ធបានដោះស្រាយទៅលើមតិយោបល់ ធាតុចូល និងសំណូមពរនានានេះដែលធ្វើឡើងដោយអ្នកពាក់ព័ន្ធ ។<br>ង- ការចូលរួមជាសាធារណៈត្រូវមានលក្ខណៈសមស្រប និងដើម្បីធ្វើការសម្រេចចិត្ត ឬការផ្តល់ការឯកភាពណាមួយ ។<br>ច. រាល់គម្រោងអភិវឌ្ឍ និងផែនការវិនិយោគបាននិងកំពុងអនុវត្ត ដោយពុំមានការចូលរួមជាសាធារណឬមិនបានពេញលេញ ត្រូវតែរៀបចំផែនការនិងអនុវត្តការចូលរួមជាសាធារណឲ្យបានពេញលេញក្នុងរយៈពេល៦០ថ្ងៃ បន្ទាប់ចូលធរមាននៃក្រមនេះ ។ | *ផែនការសម្រាប់ការចូលរួមជាសាធារណៈ ត្រូវកំណត់ និងរៀបចំឡើង ដើម្បីធានាថាអ្នកពាក់ព័ន្ធ អ្នកទទួលរងផលប៉ះពាល់ និងភាគីដែលមានចំណាប់អារម្មណ៍ ចូលរួមយ៉ាងពេញលេញ និងសកម្ម។*<br>១- អ្នកពាក់ព័ន្ធត្រូវទទួលបានការជូនដំណឹង និងពេលវេលាគ្រប់គ្រាន់ សម្រាប់ចូលរួមនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចដែលពាក់ព័ន្ធ ។<br>២- អ្នកពាក់ព័ន្ធទាំងអស់ត្រូវទទួលបានព័ត៌មានចាំបាច់ ។ ការផ្តល់ព័ត៌មានទាំងនោះត្រូវយកចិត្តទុកដាក់អំពីភាសាដែលអាចយល់បាន និងវប្បធម៌របស់អ្នកពាក់ព័ន្ធ ។<br>៣- ចំណេះដឹងខាងផ្នែកបច្ចេកទេស វិទ្យាសាស្ត្រ និងចំណេះដឹងលក្ខណៈប្រពៃណីនៃសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ត្រូវយកជាមូលដ្ឋានក្នុងការបង្កើតគម្រោង ផែនការសកម្មភាព និងការធ្វើសេចក្តីសម្រេច ។<br>៤- កិច្ចដំណើរការនៃការចូលរួមជាសាធារណៈ ត្រូវយកចិត្តទុកដាក់អំពីតម្រូវការ និងតម្លៃរបស់អ្នកពាក់ព័ន្ធ ។ |

| | | | |
|---|---|---|---|
| | | | ៥- អ្នកពាក់ព័ន្ធត្រូវទទួលបានពេលវេលាសមស្រប និងត្រឹមត្រូវ ដើម្បីធ្វើការវាយតម្លៃ និងឆ្លើយតបចំពោះព័ត៌មានទាក់ទងនឹងគម្រោងស្នើសុំសកម្មភាព ផែនការ ឬសេចក្តីសម្រេចណាមួយ ។<br>៦- កម្រិតនៃការចូលរួមជាសាធារណៈ ត្រូវស្របតាមកម្រិតនៃការចាប់អារម្មណ៍របស់អ្នកពាក់ព័ន្ធ។<br>៧- ដំណើរការនៃការចូលរួមជាសាធារណៈ ត្រូវមានភាពបត់បែន និងអាចកែសម្រួលបាន ដើម្បីឆ្លើយតបទៅនឹងការរំពឹងទុកដែលសមហេតុផលរបស់អ្នកពាក់ព័ន្ធ ។<br>~~៧- កិច្ចដំណើរនៃការចូលរួមជាសាធារណៈ ត្រូវមានលក្ខណៈបត់បែន និងអាចសម្របសម្រួលបាន ស្របតាមការរំពឹងទុករបស់អ្នកពាក់ព័ន្ធ ។~~ (ចំណុចលេខ៧ គួរតែលុបចេញ ការដែលបញ្ជាក់ថាមានការបត់បែន នោះហាក់ដូចជាពុំមានន័យក្នុងផ្លូវច្បាប់ ឬអាចបើកឲ្យមានការគិតនិងធ្វើផ្សេងទៅវិញ)<br>៨- គ្រប់មតិយោបល់របស់សាធារណជន ត្រូវទទួលបានការពិចារណានៅក្នុងដំណើរការនៃ |

| | | | |
|---|---|---|---|
| | | | ការធ្វើសេចក្តីសម្រេច ។ ការទទួលយក ឬ បដិសេធចំពោះមតិយោបល់ខាងលើនេះ ត្រូវបញ្ជាក់ហេតុផលសមរម្យ ។<br>*រាល់ព័ត៌មាន និងលទ្ធផលនៃកិច្ចដំណើរការចូលរួមជាសាធារណៈ ត្រូវផ្សព្វផ្សាយជាសាធារណៈ ស្របទៅតាមកម្រិត និងការរំពឹងទុករបស់អ្នកពាក់ព័ន្ធ។*<br>៩- រាល់គម្រោងអភិវឌ្ឍ និងផែនការវិនិយោគបាននិងកំពុងអនុវត្ត ដោយពុំមានការចូលរួមជាសាធារណឫមិនបានពេញលេញត្រូវផ្អាកជាបណ្តោះអាសន្ន និង ត្រូវរៀបចំផែនការនិងអនុវត្តការចូលរួមជាសាធារណឲ្យបានពេញលេញក្នុងរយៈពេល៦០ថ្ងៃ បន្ទាប់ពីក្រមនេះចូលជាធរមាន។ |
| ៦ | **មាត្រា២៥** ._ នីតិវិធីសម្រាប់ការចូលរួមជាសាធារណៈ<br>ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីសម្រាប់ការចូលរួមសាធារណៈ ។ ក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីសម្រាប់ការចូលរួមជាសាធារណៈ ទាក់ទងនឹងវិស័យនីមួយរបស់ខ្លួន ស្របតាម បទប្បញ្ញត្តិនៅក្នុងមាតិកានេះ ។ | **មាត្រា២៥** ._ នីតិវិធីសម្រាប់ការចូលរួមជាសាធារណៈ<br>ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីសម្រាប់ការចូលរួមសាធារណៈ និងបង្កើតបរិយាកាសអំណោយផល សំរាប់ការចូលរួមជាសធារណៈ។ ក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវបង្កើតលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីសម្រាប់ការចូលរួមជាសាធារ | ក្នុងពង្រាងទី១០ មាត្រាទី២៤<br>មិនទាន់ដាក់បញ្ចូលយោបល់ លើសេចក្តីព្រាងទី៩.១<br><br>**សំណូមពរបន្ថែម៖**<br><br>មាត្រា២៤ ._ **នីតិវិធីសម្រាប់ការចូលរួមជាសាធារណៈ**<br>ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីសម្រាប់ការចូលរួមសាធារណៈ *ចំពោះដំណើរការ និងសេចក្តីសម្រេចពាក់ព័ន្ធនឹង បរិស្ថាន និង* |

| | | | |
|---|---|---|---|
| | | ណៈ ទាក់ទងនឹងវិស័យនីមួយរបស់ខ្លួន ស្រប តាម បទប្បញ្ញត្តិនៅក្នុងមាតិកានេះ ។ | *ធនធានធម្មជាតិ ដោយបង្កឱ្យមានលក្ខណៈ និងបរិយាកាស អំណោយផល សម្រាប់ការចូលរួមជាសាធារណៈ*។ ក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីសម្រាប់ការចូលរួមជាសាធារណៈ ទាក់ទងនឹងវិស័យនីមួយៗរបស់ខ្លួន ស្របតាមបទប្បញ្ញត្តិនៅក្នុងមាតិកានេះ ។ |
| ៧ | **មាត្រា២៦** ._ ការចូលរួមប្រកបដោយប្រសិទ្ធភាពនៃជនជាតិដើមភាគតិច<br>ម្ចាស់គម្រោង ឬ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់ឱកាសឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់ជនជាតិដើមភាគតិច ដែលអាចទទួលរងផលប៉ះពាល់ដោយសេចក្តីសម្រេចទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ និងត្រូវតែទទួលបាននូវការយល់ព្រមដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយរបស់ពួកគេ មុនពេលដែលសេចក្តីសម្រេចនោះត្រូវបានធ្វើឡើង ។ ការចូលរួមត្រូវតែផ្តល់ជូនឱ្យបានទាន់ពេលវេលា ហើយអ្នកចូលរួមត្រូវទទួលបានការជូនដំណឹងពេញលេញអំពីព័ត៌មានពាក់ព័ន្ធទាំងអស់ នៅក្នុងទម្រង់ និងភាសាដែលសមរម្យ ។ | **មាត្រា២៦** ....ការចូលរួមប្រកបដោយប្រសិទ្ធភាពនៃជនជាតិដើមភាគតិច<br>ម្ចាស់គម្រោង ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់ឱកាសអំណោយផលឱ្យមានការចូលរួមប្រកបដោយប្រសិទ្ធភាពនិងពេញលេញរបស់ជនជាតិដើមភាគតិច លើសពី ២ភាគ៣ដែលអាចទទួលរងផលប៉ះពាល់ពីសេចក្តីសម្រេចទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ។ ជនជាតិដើមភាគតិចដែលអាចរងផលប៉ះពាល់ពីគម្រោងស្នើរសុំ មានសិទ្ធិពេញលេញក្នុងការចូលរួមនៅគ្រប់ដំណាក់កាលរបស់គម្រោង ដោយគ្មានការបង្ខិតបង្ខំ ឬការគម្រាមកម្ហែង។ | ក្នុងពង្រាងទី១០ មាត្រាទី២៧<br><br>ស្នើឱ្យពិនិត្យបន្ថែមមតិយោបល់របស់សង្គមស៊ីវិល លើពង្រាងទី៩.១ |

<table>
<tr>
<td>៨</td>
<td>មាត្រា២៨ ._ នីតិវិធីសម្រាប់ការចូលរួមរបស់សហាគមន៍ជនជាតិដើមភាគតិច<br><br>ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបង្កើតឧបករណ៍គតិយុត្តស្តីពីនីតិវិធីសម្រាប់ការពិគ្រោះយោបល់ និងការចូលរួមជាសាធារណៈរបស់ជនជាតិដើមភាគតិច នៅក្នុងការសម្រេចចិត្ត ដែលប៉ះពាល់ដល់ដី និងសហាគមន៍របស់ជនជាតិដើមភាគតិច ។</td>
<td>មាត្រា២៨ ._ នីតិវិធីសម្រាប់ការចូលរួមរបស់សហាគមន៍ជនជាតិដើមភាគតិច<br><br>ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបង្កើតឧបករណ៍គតិយុត្តស្តីពីនីតិវិធីអំណោយផលសម្រាប់ការពិគ្រោះយោបល់ និងការចូលរួមជាសាធារណៈរបស់ជនជាតិដើមភាគតិច នៅក្នុងការសម្រេចចិត្ត ដែលប៉ះពាល់ដល់ដី និងសិទ្ធិជាមូលដ្ឋានសហាគមន៍របស់ជនជាតិដើមភាគតិច ។</td>
<td>ស្នើដាក់បញ្ចូល៖<br><br>មាត្រា២៨ ._ នីតិវិធីនៃការចូលរួមរបស់សហាគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច<br><br>នីតិវិធីនៃការពិគ្រោះយោបល់ ការចូលរួម និងយល់ព្រមចំពោះការធ្វើសេចក្តីសម្រេច ដែលប៉ះពាល់ចំពោះដីធ្លី និងធនធានរបស់សហាគមន៍មូលដ្ឋាន និងជាតិដើមភាគតិច ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ ដោយមានលក្ខណៈសមស្រប និងធានាបាននូវបុព្វសិទ្ធិ និង សិទ្ធិជាមូលដ្ឋានរបស់ពួកគាត់ ។</td>
</tr>
<tr>
<td>៩</td>
<td colspan="3">មតិយោបល់ថ្មី នៃពង្រាងទី១០<br>មាត្រា៣៣ ._ កាតព្វកិច្ចក្នុងការបើកបង្ហាញ និងដាក់ព័ត៌មានឱ្យសាធារណជនអាចស្វែងរកបាន<br>គ្រប់ម្ចាស់គម្រោង ឬក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវបើកបង្ហាញព័ត៌មាន ដូចមានចែងក្នុងមាត្រា៣៥ នៃក្រមនេះ ឱ្យ យ៉ាងហោចណាស់ ៣០ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីឲ្យសាធារណជនអាចស្វែងរកបាន មុនពេលចេញ៖<br><br>មាត្រា៣៥ ._ ព័ត៌មានពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ<br>ព័ត៌មានពាក់ព័ន្ធនឹងបញ្ហាបរិស្ថាន និងធនធានធម្មជាតិមានដូចខាងក្រោម៖<br>ស្នើពិចារណាដាក់បញ្ចូលលក្ខខណ្ឌការងារសម្រាប់កិច្ចដំណើរការការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផែនការគ្រប់គ្រងបរិស្ថាន</td>
</tr>
</table>

| | |
|---|---|
| | ១៣- រាល់ព័ត៌មានពាក់ព័ន្ធផ្សេងទៀត ~~កំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុក~~ ~~បរិស្ថាន~~ ដែលមិនស្ថិតក្នុងប្រភេទព័ត៌មានសម្ងាត់ដែលកំណត់ដោយក្រមនេះ។<br><br>**មាត្រា៣៦** ._ ព័ត៌មានសាធារណៈ<br>**ជំពូកទី២៖ ការផ្តល់ព័ត៌មានដោយរាជរដ្ឋាភិបាល**<br>**ផ្នែកទី១៖ ការផ្តល់ព័ត៌មានជាសាធារណៈ**<br>**មាត្រា៣៨** ._ ការផ្តល់ព័ត៌មានជាសាធារណៈ<br>គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់ព័ត៌មានគ្រប់ទម្រង់រួមទាំងកំណត់ត្រា ឯកសារបោះពុម្ពផ្សាយ សម្លេង កាសែត ឯកសារអេឡិចត្រូនិច ជាសាធារណៈនូវរាល់ប្រភេទព័ត៌មាន ដូចមានចែងក្នុងមាត្រា៣៥ នៃក្រមនេះ ។<br>**មាត្រា៣៩** របាយការណ៍បរិស្ថានជាតិ (សូមធ្វើកំណែការសសេរ)<br>ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំរបាយការណ៍បរិស្ថានជាតិ រៀងរាល់ប្រាំ(៥)ឆ្នាំ ម្តង។ របាយការណ៍បរិស្ថានជាតិ ត្រូវរួមបញ្ចូលព័ត៌មានបរិស្ថានពាក់ព័ន្ធ និងការវាយតម្លៃការអនុវត្តគោលនយោបាយ និងច្បាប់បរិស្ថាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។<br><br>**មាត្រា៤៣** ._ ប្រភេទព័ត៌មាន នៃបញ្ជីព័ត៌មានបរិស្ថានជាតិ<br>បញ្ជីព័ត៌មានបរិស្ថានជាតិនេះ ត្រូវដាក់បញ្ចូលនូវព័ត៌មានទាំងអស់ដែលផ្តល់ឱ្យដោយក្រសួង ស្ថាប័នសមត្ថកិច្ច ស្របតាមលក្ខខណ្ឌតម្រូវនៃក្រមនេះ ។<br>ប្រភេទព័ត៌មានបរិស្ថាន និងធនធានធម្មជាតិ រួមមាន ស្ថិតិ របាយការណ៍រីកចម្រើននិងថវិកា និងព័ត៌មានភូមិសាស្ត្រស្តីពីបរិស្ថាន ស្ថានភាពនៃប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ និងធនធានធម្មជាតិ សកម្មភាពអភិវឌ្ឍ និងសិទ្ធិកាន់កាប់ដីធ្លីរបស់សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច ជាអាទិ៍ ។ |

## ផ្នែកទី៣
## មជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ
## មជ្ឈមណ្ឌលពត៌មានភូមិសាស្ត្របរិស្ថានជាតិ

អត្ថន័យនេះហាក់មិនទូលំទូលាយ និងមិនសមស្របតាមភាពទំនើបនៃវិស័យពត៌មានវិទ្យាទេ ខ្ញុំគិតគួរកែដាក់ថា មជ្ឈមណ្ឌលពត៌មានភូមិសាស្ត្របរិស្ថានជាតិ។ ផែនទីជាទូទៅសំដៅលើផលិតផលសម្រេចមានទម្រង់ដូចជាក្រដាស ដែលខ្វះនូវភាពបត់បែន ក្នុងវិភាគនិងយកមកប្រើប្រាស់ពហុបំណង (ឧទ. មូលដ្ឋានទិន្នន័យផ្សេងៗ) ។ ជាពិសេសវាមិនស៊ីគ្នាជាមួយអត្ថន័យក្នុងមាត្រាបន្តបន្ទាប់។ ប្រសិនកែប្រែឈ្មោះ សូមកែទាំងអស់!

**មាត្រា៤៧** ._ ការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ

សូមកែសម្រួលនិងបន្ថែមចំណុច៥ក្នុងមាត្រានេះដើម្បីឲ្យមានភាពពេញលេញ និងល្អសមស្របថាជាមជ្ឈមណ្ឌលជាតិ ដូចខាងក្រោម៖

ការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលផែនទីបរិស្ថានជាតិ មានដូចខាងក្រោម៖

១- គ្រប់គ្រងបញ្ជីព័ត៌មានបរិស្ថានជាតិ ដោយថែរក្សា និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យ និងទទួលព័ត៌មានពាក់ព័ន្ធមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ។

២- មានមុខងារក្នុងការសម្រិតសម្រាំងស្ថិតិ ទិន្នន័យមូលដ្ឋានបរិស្ថាន ទិន្នន័យភូមិសាស្ត្រនៃដូចជាការប្រើប្រាស់ដី តំបន់ការពារធម្មជាតិ ព្រៃឈើ ជីវៈចម្រុះ និងព័ត៌មានភូមិសាស្ត្រផ្សេងៗទៀត~~ផែនទី~~ ដែលផ្ដល់ឱ្យដោយក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត រៀបចំ និងរក្សាបញ្ជីទិន្នន័យ ព័ត៌មានសម្រាប់ទំនាក់ទំនង និងបែបបទក្នុងសម្រាប់ការស្នើសុំទិន្នន័យ ។

៣- ធ្វើការវិភាគទិន្នន័យ ឬព័ត៌មានដែលប្រើប្រាស់ជាមូលដ្ឋានក្នុងការធ្វើសេចក្ដីសម្រេចដែលពាក់ព័ន្ធនឹងបរិស្ថាន និងធនធានធម្មជាតិ ។

៤- ចងក្រង និងបញ្ចូលទិន្នន័យមូលដ្ឋាន និងភូមិសាស្ត្រនៃផ្សេងៗដូចជាការប្រើប្រាស់ដី តំបន់ការពារធម្មជាតិ ព្រៃឈើ ជីវចម្រុះ និងរបាយការណ៍ពាក់ព័ន្ធនឹងការកំណត់ផែនទីបរិស្ថាន និងធនធានធម្មជាតិ ដែលរៀបចំដោយក្រសួង ស្ថាប័នពាក់ព័ន្ធទៅក្នុងបញ្ជីព័ត៌មានបរិស្ថានជាតិ ។

៥- រៀបចំស្តង់ដារនានាសម្រាប់ការប្រមូល ការចូលរួមប្រមូលទិន្នន័យ ការគ្រប់គ្រង ការវិភាគ និងការបែងចែក ព័ត៌មានភូមិសាស្ត្រនៃការប្រើប្រាស់ដី តំបន់ការពារធម្មជាតិ ព្រៃឈើ ជីវចម្រុះ ។

៦- កំណត់ទម្រង់ស្តង់ដារបច្ចេកទេសសម្រាប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការផ្តល់ទិន្នន័យ ។

៧- កំណត់ទិន្នន័យភូមិសាស្ត្រនៃការប្រើប្រាស់ដី តំបន់ការពារធម្មជាតិ ព្រៃឈើ ជីវចម្រុះ ដោយមានការធានាគុណភាព និងដោយភ្ជាប់មកជាមួយនូវបណ្តុំទិន្នន័យដែលមានស្រាប់។

៨- ប្រមូលទិន្នន័យភូមិសាស្ត្រនៃការប្រើប្រាស់ដីតំបន់ការពារធម្មជាតិ ព្រៃឈើ ជីវចម្រុះ និងទិន្នន័យពាក់ព័ន្ធនឹងវិស័យជាក់លាក់ណាមួយ ។ ការប្រមូលនេះ មិនត្រូវជាន់គ្នានឹងព័ត៌មាន ឬទិន្នន័យ ក្នុងចំណោមក្រសួង ស្ថាប័ននានាឡើយ ។

៩- ចងក្រង កត់ត្រា ទុកដាក់និងចែករំលែកនូវពត៌មានទិន្នន័យមូលដ្ឋាន ពត៌មានភូមិសាស្ត្រអំពីគម្រោងអភិវឌ្ឍនានា គម្រោងអភិវឌ្ឍន៍នានាក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានកិច្ចសន្យាការពារបរិស្ថាន ការវាយតម្លៃបឋមបរិស្ថាន និងការវាយតម្លៃបរិស្ថានពេញលេញ។

**មាត្រា៥៣** ._ ការរៀបចំបញ្ជីសរនេកម្មបរិស្ថានថ្នាក់ជាតិ

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំបញ្ជីសរនេកម្មបរិស្ថានថ្នាក់ជាតិនិងធ្វើបច្ចុប្បន្នភាពជាប្រចាំ ដោយធ្វើការបោះពុម្ពរៀងរាល់ឆ្នាំ។ (សូមកែសម្រួល)

**មាត្រា៥៩** ._ ការកំណត់អំពីព័ត៌មានសម្ងាត់

ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវសម្រេចយល់ព្រម ឬបដិសេធលើសំណើសុំចាត់ទុកព័ត៌មានណាមួយជាព័ត៌មានសម្ងាត់ ដោយត្រូវបញ្ជាក់ហេតុផលជាលាយលក្ខណ៍អក្សរ។ ការធ្វើសេចក្តីសម្រេចនេះ ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ។

នីតិវិធីសម្រាប់ការកំណត់ព័ត៌មានណាមួយជាព័ត៌មានសម្ងាត់ ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ។

ក្នុងករណីផលប្រយោជន៍សាធារណៈធំជាងការរក្សាទុកព័ត៌មានសម្ងាត់ ដូចមានចែងក្នុងបទប្បញ្ញត្តិហាមឃាត់ ព័ត៌មានសម្ងាត់នោះត្រូវតែផ្តល់ជូនសាធារណជនប្រើប្រាស់តាមការស្នើសុំ។

ប្រភេទព័ត៌មានសម្ងាត់នីមួយៗគួរបញ្ជាក់ក្នុងជំពូកនេះឲ្យបានច្បាស់លាស់ ជៀសវាងការបកស្រាយផ្សេងៗគ្នា។

សម្គាល់៖ សេចក្តីព្រាងច្បាប់នេះមានការចែងគោរពតាមគោលការណ៍សិទ្ធិទទួលព័ត៌មានច្រើនគួរសម និង មានមាត្រាជាច្រើនដែលចែងអំពីព័ត៌មាន រួមទាំងមានទោសទណ្ឌសម្រាប់ស្ថាប័នសាធារណៈក្នុងការអនុវត្តការមិនផ្តល់ព័ត៌មានជូនសាធារណជនទៀតផង។
យ៉ាងណាមិញនៅក្នុងផ្នែកបណ្តឹង ហាក់ដូចជាពុំឃើញមានយន្តការបណ្តឹងជាក់លាក់ដែលពាក់ព័ន្ធនឹងការមិនផ្តល់ព័ត៌មានឡើយ ដូច្នេះគួរមានផ្នែកនេះជាពិសេសគឺយន្តការដែលនៅកៀកប្រជាពលរដ្ឋបំផុត ដូចជា ការិយាល័យប្រជាពលរដ្ឋ ក្រុមប្រឹក្សាមូលដ្ឋានជាដើម។

**មាត្រា៦៣ ._ នីតិវិធីស្នើសុំព័ត៌មាន**

ក្រសួង ស្ថាប័នពាក់ព័ន្ធអាចរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីនីតិវិធីស្នើសុំព័ត៌មាន ។

នីតិវិធីស្នើសុំព័ត៌មាន ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ ។

ចំណុចពិចារណា៖ តើនីតិវិធីនេះ គួរតែមានកំណត់ពេលវេលានៃការឆ្លើយតបដែរឬទេ ? ហើយតើនីតិវិធីនេះ សមស្របសម្រាប់សហគមន៍មូលដ្ឋានដែរឬទេ ( គោលការណ៍នៃការចូលរួមជាសាធារណៈ ) ?

**មាត្រា៦៤** ._ ក្របខ័ណ្ឌនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត

គោលនយោបាយ ផែនការ និងកម្មវិធីនានា តាមវិស័យ ប្រធានបទ ឬតាមតំបន់ភូមិសាស្រ្ត ដែលបានរៀបចំឡើងដោយក្រសួង ស្ថាប័នមានសមត្ថកិច្ច ត្រូវធ្វើការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ មុនបញ្ជូនទៅរាជរដ្ឋាភិបាលសម្រេច ។ (សូមបន្ថែមពត៍មាន )

**មាត្រា៦៥** ._ វិសាលភាព

ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត មានវិសាលភាពអនុវត្តចំពោះគោលនយោបាយ ផែនការ និងកម្មវិធីដូចខាងក្រោម៖

១. អាចបង្កផលប៉ះពាល់គួរឱ្យកត់សម្គាល់ចំពោះបរិស្ថាន ។

២. ពាក់ព័ន្ធនឹងវិស័យ ប្រធានបទ ឬតំបន់ភូមិសាស្រ្តដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្តស្តីពីលក្ខណៈវិនិច្ឆ័យនៃការធ្វើចំណាត់ថ្នាក់ របស់ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ។(សូមបន្ថែមពត៍មាន )

**មាត្រា៦៨** ._ ការរៀបចំគោលនយោបាយ ផែនការ និងកម្មវិធី

ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត ត្រូវធ្វើឡើងមុនឬដំណាលគ្នាជាមួយនឹងការរៀបចំគោលនយោបាយ ផែនការ និងកម្មវិធីដែលត្រូវធ្វើការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត (សូមបន្ថែមពត៍មាន)

**មាត្រា៦៩** ._ នីតិវិធីនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត

នីតិវិធីនៃការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត ត្រូវអនុវត្តតាមដំណាក់កាល ដូចខាងក្រោមៈ

១- ការធ្វើចំណាត់ថ្នាក់និងជំរើសនៃកិច្ចអភិវឌ្ឍន៍ (សូមបន្ថែមពត៍មាន)

២- ការកំណត់វិសាលភាព

៣- ការរៀបចំរបាយការណ៍ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត

៤- ការពិនិត្យ ផ្តល់យោបល់ និងឯកភាពលើរបាយការណ៍ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត

៥- ការអនុវត្តរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត ចំពោះគោលនយោបាយ ផែនការ និងកម្មវិធី និង

៦- ការអង្កេតតាមដាន ការវាយតម្លៃ និងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត ចំពោះគោលនយោបាយ ផែនការ និង កម្មវិធី ។

**មាត្រា៧០** ._ ក្រសួង ស្ថាប័នទទួលបន្ទុករៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត

ក្រសួង ស្ថាប័នមានសមត្ថកិច្ចតាមវិស័យ ឬតាមតំបន់ភូមិសាស្រ្ត ត្រូវរៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធ សាស្រ្ត និងដាក់ជូនក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ដើម្បីពិនិត្យ ផ្តល់យោបល់ និងឯកភាព ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ចតាមវិស័យ អាចរៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធ សាស្រ្តដោយខ្លួនឯង ឬជួលទីប្រឹក្សាដែលទទួលស្គាល់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដើម្បីរៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្រ្ត ។

**មាត្រា៧១ ._** ការធ្វើសេចក្តីសម្រេចលើរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

បន្ទាប់ពីបានធ្វើការពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវធ្វើសេចក្តីសម្រេច ដូចខាងក្រោម ៖

១- ផ្តល់យោបល់ និងបង្គាប់ឱ្យកែសម្រួល ឬកែតម្រូវរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រជាមុនសិន មុនពេលបញ្ជូនរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រសាជាថ្មី ដើម្បីពិនិត្យ និងផ្តល់យោបល់ម្តងទៀត ឬ

២- ផ្តល់ការឯកភាពលើរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ <u>និងអនុសាសន៍សំខាន់ៗដើម្បីក្រសួង ស្ថាប័នមានសមត្ថកិច្ចយកទៅអនុវត្ត។</u>

**មាត្រា៧៧ ._** ការដាក់បញ្ចូលលទ្ធផលនៃការរៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ

ក្រសួង ស្ថាប័នមានសមត្ថកិច្ច ដែលរៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រត្រូវ ៖

១- ត្រូវដាក់បញ្ចូលលទ្ធផលនៃការរៀបចំរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងមតិយោបល់កែសម្រួលរបស់ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាពទៅក្នុងគោលនយោបាយ ផែនការ និងកម្មវិធី មុននឹងបញ្ចប់របាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និង

២- បង្ហាញអំពីរបៀបដែលលទ្ធផលនៃការរៀបចំរបាយការណ៍ និងមតិយោបល់អំពី ការកែសម្រួល ឬមិនកែសម្រួល <u>ជាពិសេសបង្ហាញពីដំណើរការសំខាន់ៗដើម្បីដោះស្រាយបញ្ហានិងការអនុវត្ត។</u>

**មាត្រា៧៨ ._** ការអង្កេតតាមដាន

ក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន <u>និងការចូលរួមពីសហគមន៍ឬប្រជាជនពាក់កព័ន្ធ</u> ត្រូវរៀបចំកម្មវិធីដើម្បីអង្កេតតាមដានហេតុប៉ះពាល់បរិស្ថាន នៅក្នុងការអនុវត្ត គោលនយោបាយ ផែនការ និងកម្មវិធី ដូចមានកំណត់នៅក្នុងរបាយការណ៍វាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តស្តីពីការអង្កេតតាមដានការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រនៃក្រមនេះ ។

| | |
|---|---|
| | **មាត្រា៨៨** ._ ការរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន<br>ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីគាំទ្រការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដោយដាក់បញ្ចូលចំណុចដូចខាងក្រោមៈ<br>១- កំណត់លក្ខណៈវិនិច្ឆ័យនៃការធ្វើចំណាត់ថ្នាក់គម្រោង និងជម្រើសនានាដើម្បីកំណត់អំពីកម្រិតនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងដែលមានស្រាប់ ឬគម្រោងកំពុងដំណើរការ និងគម្រោងស្នើសុំ ក្រោយពេលក្រមនេះចូលជាធរមាន ។<br>២- នីតិវិធី លក្ខខណ្ឌតម្រូវ ខ្លឹមសារអប្បបរមា និងទម្រង់បែបបទ សម្រាប់ការរៀបចំការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន របាយការណ៍នៃការកំណត់វិសាលភាពគម្រោង លក្ខខណ្ឌការងារ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ការរៀបចំផែនការគ្រប់គ្រងបរិស្ថាន កិច្ចសន្យាការពារបរិស្ថាន និងផែនការគាំពារបរិស្ថាន ។<br>៣- នីតិវិធី លក្ខខណ្ឌតម្រូវ និងលក្ខណៈវិនិច្ឆ័យ ខ្លឹមសារ និងទម្រង់បែបបទសម្រាប់ការរៀបចំរបាយការណ៍វាយតម្លៃហានិភ័យ ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងគុណវិឌ្ឍិរបស់ទីប្រឹក្សាវាយតម្លៃហានិភ័យដែលមានការទទួលស្គាល់ក្នុងការរៀបចំរបាយការណ៍វាយតម្លៃហានិភ័យ ដោយប្រើប្រាស់ទម្លាប់អនុវត្តល្អបំផុត និងគោលការណ៍នៃការវាយតម្លៃហានិភ័យដែលមានលក្ខណៈវិទ្យាសាស្ត្រ ។ ការវាយតម្លៃហានិភ័យជាផ្នែកមួយនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។<br>៤- នីតិវិធី លក្ខខណ្ឌតម្រូវ និងលក្ខណៈវិនិច្ឆ័យ ខ្លឹមសារ និងទម្រង់បែបបទធ្វើសវនកម្មបរិស្ថាន ការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នមានសមត្ថកិច្ច និងគុណវុឌ្ឍិសម្រាប់ការចុះបញ្ជី និងការទទួលស្គាល់សវនករបរិស្ថាន ។<br>៥- នីតិវិធី លក្ខខណ្ឌតម្រូវ និងលក្ខណៈវិនិច្ឆ័យ ខ្លឹមសារ និងទម្រង់បែបបទសម្រាប់ការរៀបចំរបាយការណ៍វាយតម្លៃហានិភ័យដោយចីរភាព ។<br>៦- ការបង្កើត និងមុខងាររបស់គណៈកម្មាធិការជំនាញត្រួតពិនិត្យ ដោយគិតតាមវិធានបរិស្ថាន។<br>៧- នីតិវិធី និងលក្ខខណ្ឌតម្រូវសម្រាប់ការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន រួមទាំងគោលការណ៍ណែនាំស្តីពីការចូលរួមជាសាធារណៈ ។ |

៨- នីតិវិធីសម្រាប់ការផ្លាស់ទីលំនៅថ្មី និងការសងសំណងការខូចខាតចំពោះអ្នកទទួលរងផលប៉ះពាល់ពីគម្រោង ដោយមានការពិគ្រោះពិភាក្សាជាមួយអ្នកធ្លាប់រងគ្រោះថ្នាក់ ឬសហគមន៍មូលដ្ឋានផ្ទាល់ ។

៩- កំណត់លក្ខខណ្ឌ គុណវុឌ្ឍិ ទម្រង់បែបបទ និងនីតិវិធីសម្រាប់ការចុះបញ្ជីទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

១០- រៀបចំ បង្កើតក្របខ័ណ្ឌគតិយុត្ត សម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន រួមមាន លិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំ និងវិធីសាស្ត្រនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្លងដែន ។

១១- ការណែនាំ និងលក្ខខណ្ឌតម្រូវសម្រាប់ម្ចាស់គម្រោង និងស្ថាប័នមានសមត្ថកិច្ច ទាក់ទងនឹងសវនកម្មបរិស្ថាន ការអង្កេតតាមដាន និងការរៀបចំរបាយការណ៍ ។

( សូមកែសម្រួលនិងបន្ថែមពត៍មាន នេះដើម្បីឲ្យមានសុគតភាពដូចចែងក្នុងមាត្រា១២១ )

**មាត្រា៩១** ._ សមាសភាពនៃគណៈកម្មាធិការជំនាញត្រួតពិនិត្យ

សមាសភាពនៃគណៈកម្មាធិការជំនាញត្រួតពិនិត្យ រួមមានៈ

១- មន្ត្រីបច្ចេកទេសពី~~ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ក្រសួង ស្ថាប័នមានសមត្ថកិច្ច និង~~រដ្ឋបាលថ្នាក់ក្រោមជាតិ និងតំណាងអ្នកជំនាញពីសហគមន៍ពាក់ព័ន្ធ ។

២- អ្នកជំនាញបច្ចេកទេសឯករាជ្យដែលមានគុណវុឌ្ឍិ និងបទពិសោធន៍ត្រួតពិនិត្យលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ។

៣- តំណាងពីក្រសួង ស្ថាប័នទទួលបន្ទុកកិច្ចការនារី ។

៤- តំណាងពីអង្គការមិនមែនរដ្ឋាភិបាល

៥- តំណាងសកលវិទ្យាល័យ វិទ្យាស្ថានឬ មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវពីវិស័យដែលពាក់ព័ន្ធ។

សមាជិកគណៈកម្មាធិការជំនាញត្រួតពិនិត្យ អាចមានការប្រែប្រួលពីគម្រោងមួយទៅគម្រោងមួយ តាមការជ្រើសរើសរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន អាស្រ័យទៅតាមទិដ្ឋភាពច្ចេកទេសនៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជំនាញត្រួតពិនិត្យស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា៩៥** ._ ការទទួលខុសត្រូវចំពោះការអនុវត្ត ឬមិនអនុវត្តគម្រោង~~ធ្វើ ឬមិនធ្វើសកម្មភាព~~

ម្ចាស់គម្រោងត្រូវទទួលខុសត្រូវទាំងស្រុងផ្នែកហិរញ្ញវត្ថុ និងផ្លូវច្បាប់ចំពោះការអនុវត្តន៍ឬមិនអនុវត្ត ~~ធ្វើ ឬមិនធ្វើ~~សកម្មភាពរបស់ខ្លួន ។

ម្ចាស់គម្រោងត្រូវទទួលខុសត្រូវទាំងស្រុងផ្នែកហិរញ្ញវត្ថុ និងផ្លូវច្បាប់ផងដែរ ចំពោះ~~ការធ្វើ ឬមិនធ្វើ~~សកម្មភាពរបស់អ្នកម៉ៅការ អ្នកម៉ៅការបន្ត មន្ត្រី កម្មករនយោជិក ភ្នាក់ងារ អ្នកតំណាង និងទីប្រឹក្សា ដែលម្ចាស់គម្រោងបានផ្តល់ការងារឱ្យ ឬជួល ឬផ្តល់សិទ្ធិអំណាចឱ្យអនុវត្តការងារគម្រោងជំនួសខ្លួន ។

**មាត្រា៩៦** ._ កាតព្វកិច្ចក្នុងការអនុវត្តតាមលក្ខខណ្ឌនៃលិខិត និងវិញ្ញាបនបត្រឯកលើភាពរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន

ម្ចាស់គម្រោង ត្រូវអនុវត្តតាមការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ  ឬកិច្ចសន្យាការពារបរិស្ថាន និងលក្ខខណ្ឌ និងការប្តេជ្ញាចិត្តពាក់ព័ន្ធនឹងគម្រោង ។

ម្ចាស់គម្រោង ត្រូវទទួលខុសត្រូវ និងតម្រូវឱ្យអ្នកម៉ៅការ និងអ្នកម៉ៅការបន្តនៃគម្រោង អនុលោមតាមកាតព្វកិច្ចទាំងអស់ ដូចមានកំណត់នៅក្នុងលិខិត និងវិញ្ញាបនបត្រឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន ផែនការគ្រប់គ្រងបរិស្ថាន ផែនការគាំពារបរិស្ថាន លក្ខខណ្ឌ និងការប្តេជ្ញាចិត្តទាំងអស់របស់គម្រោង ។

ម្ចាស់គម្រោងត្រូវបានជំរុញនិងលើកទឹកចិត្តក្នុងការគិតគូរ អនុវត្តល្អៗជាប្រចាំដើម្បីបង្កើនគុណភាពបរិស្ថាននិងសង្គមពាក់ព័ន្ធនិងគម្រោងខ្លួន។

**មាត្រា១០៦ ._** សុពលភាពនៃការចុះបញ្ជី

ការចុះបញ្ជីជាទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវមានសុពលភាពសម្រាប់រយៈពេលអតិបរមា ៥ (ប្រាំ) ឆ្នាំ និងអាចបន្តសារជាថ្មីបាន តាមការស្នើសុំរបស់ក្រុមហ៊ុនឬទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

**គន្ទីទី២ មាតិកាទី២ ជពូកទី៣៖ កិច្ចដំណើរការនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន មាត្រា១០៩ ដល់មាត្រា១៣៥**

តាមមតិយោបល់ លើសេចក្តីព្រាងទី៩.១ ស្នើសុំឱ្យមានការចូលរួមជាសាធារណៈ នៅក្នុងគ្រប់ដំណាក់កាលនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយឡែកនៅក្នុងជំពូកទី៣ នេះមិនមានការបញ្ជាក់ពីការចូលរួមជាសាធារណៈ (ជំពូកទី៥ ការចូលរួមជាសាធារណៈ ត្រូវបានលុបចោល)។ ការចូលរួមជាសាធារណៈ មានតែនៅក្នុងដំណាក់កាលកំណត់វិសាលភាព (មាត្រា១១៥) ដំណាក់កាលការវាយតម្លៃលើរបាយការណ៍ (មាត្រា១២៣) តែប៉ុណ្ណោះ។

**មាត្រា១១០._** តំបន់ដែលតម្រូវឱ្យមានការវាយតម្លៃបរិស្ថានពេញលេញ

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវរៀបចំឡើងចំពោះគម្រោងស្នើសុំ ដែលអាចបង្កផលប៉ះពាល់អវិជ្ជមាន ដែលមានទីតាំងនៅក្នុងតំបន់ដែលមានតម្លៃអភិរក្សខ្ពស់ ដូចខាង ក្រោម៖

១- តំបន់ការពារបេតិកភណ្ឌវប្បធម៌

២- សមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ

៣- ប្រព័ន្ធអេកូឡូស៊ីដែលបានកំណត់ថាកំពុងទទួលរងការវិនាស និងជម្រកសត្វព្រៃដែលស្ថិតនៅក្នុងបញ្ជីកំពុងរងគ្រោះថ្នាក់ ដូចមានចែងក្នុងគន្ថីទី៤នៃក្រមនេះ ។

៤- ប្រភពផ្គត់ផ្គង់ទឹកស្អាត តំបន់អេកូឡូស៊ីកម្រឬមានតែមួយគត់ ព្រៃកោងកាង និងតំបន់ឆ្នេរ ។

៥-តំបន់ដែលផ្តល់ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច ។

៦- ដីធ្លី ឬធនធាននានារបស់ជនជាតិដើមភាគតិច ។

**មាត្រា១១២**._ នីតិវិធីសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ (សូមកែសម្រួលនិងបន្ថែមពត៌មាន នេះដើម្បីឲ្យមានសុគតភាពដូចចែងក្នុងមាត្រា១២១)

គម្រោងដែលត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោមៈ

១- ការកំណត់វិសាលភាពគម្រោង និងពីការគិតគូរពីជម្រើសនានា ។

២- ការពិនិត្យ និងឯកភាពលើរបាយការណ៍ពីការជ្រើសរើសម្រើសដ៏ប្រសើរបំផុត កំណាត់វិសាលភាពគម្រោង និងលក្ខខណ្ឌការងារ ។

៣- ការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ។

៤-ការពិនិត្យ និងការធ្វើសេចក្តីសម្រេចលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដំបូង ឬពេញលេញ ។

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវធ្វើការពិនិត្យ និងពិចារណាលើមតិយោបល់របស់ គណៈកម្មាធិការជំនាញត្រួតពិនិត្យ រួមទាំងមតិយោបល់នៃការចូលរួមជាសាធារណៈនិងការឆ្លើយតបរបស់ម្ចាស់គម្រោងជាមុនសិន មុននឹងធ្វើការសម្រេចឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

**មាត្រា១១៤** ._ វិសាលភាព

រាល់គម្រោងដែលតម្រូវឱ្យធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ត្រូវកំណត់ពីជម្រើសដ៏ប្រសើរបំផុត វិសាលភាព និងរៀបចំរបាយការណ៍កំណត់វិសាលភាព ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ហើយត្រូវដាក់ជូនក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានដើម្បីសុំការឯកភាព ។

របាយការណ៍កំណត់វិសាលភាព ត្រូវដាក់បញ្ចូលនូវលក្ខខណ្ឌការងារសម្រាប់សិក្សាលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ។

**មាត្រា១១៥** ._ ការចូលរួមជាសាធារណៈនៅក្នុងអំឡុងពេលកំណត់វិសាលភាពគម្រោង

ម្ចាស់គម្រោង និងទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវរៀបចំឱ្យមានដំណើរការចូលរួមជាសាធារណៈ រួមជាមួយផែនការនៃការចូលរួមជាសាធារណៈរបស់គម្រោង នៅក្នុងអំឡុងពេលរៀបចំរបាយការណ៍កំណត់ពីជម្រើសដ៏ប្រសើរនានា វិសាលភាពគម្រោង និងដាក់ព័ត៌មានឱ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទបទប្បញ្ញត្តិនៃក្រមនេះ និងគោលការណ៍ណែនាំដទៃទៀត ដែលកំណត់ដោយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។

**មាត្រា១១៦** ._ លក្ខខណ្ឌការងារ

ទីប្រឹក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវធ្វើការសិក្សា និងរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ដោយផ្អែកតាមលក្ខខណ្ឌការងារដែលទទួលបានការឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។ ការកែប្រែលក្ខខណ្ឌការងារណាមួយលុះត្រាតែមានការឯកភាពជាលាយលក្ខណ៍អក្សរពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន។

**មាត្រា១១៧** ._ ការបើកបង្ហាញព័ត៌មាន

របាយការណ៍កំណត់ពីជម្រើសដ៏ប្រសើរនានា វិសាលភាព និងលក្ខខណ្ឌការងារ ដែលទទួលបានការឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវដាក់ភ្ជាប់ជាមួយរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងឱ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

**មាត្រា១១៩** ._ ការបង្ហាញព័ត៌មានអប្បបរមា

ម្ចាស់គម្រោង ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបានជាអប្បបរមា នូវរបាយការណ៍វាយតម្លៃបរិស្ថានដំបូង ឬពេញលេញ ផែនការនៃការចូលរួមជាសាធារណៈ ផែនការគ្រប់គ្រងបរិស្ថាន ផែនទី រួមទាំងមតិយោបល់និងសំណូមពីអ្នករងផលប៉ះពាល់ ផែនការ វិធានការកាត់បន្ថយផលប៉ះពាល់ដែលបានស្នើឡើង នៅក្នុងដំណាក់កាលសិក្សា វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញពេញ ដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់ដល់អ្នកពាក់ព័ន្ធ ដើម្បីពិនិត្យ និងផ្តល់យោបល់ ។

**មាត្រា១២២** ._ ផែនការគ្រប់គ្រងបរិស្ថាន

ផែនការគ្រប់គ្រងបរិស្ថាន ដែលកំណត់នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ត្រូវតែជាផែនការច្បាស់លាស់ដោយបញ្ជាក់ពីអ្នកទទួលខុសត្រូវ ពេលវេលា និងថវិការ ត្រូវដាក់ឱ្យសាធារណជនអាចស្វែងរកបាន ដើម្បីពិនិត្យ និងផ្តល់យោបល់ ។

ផែនការគ្រប់គ្រងបរិស្ថាន ត្រូវដាក់បញ្ចូលនូវកិច្ចគាំពារបរិស្ថាន វិធានការកាត់បន្ថយផលប៉ះពាល់  ការអង្កេតតាមដាន យន្តការសហការជាមួយសហគមន៍មូលដ្ឋាន យន្តការដោះស្រាយវិវាទ និងលក្ខខណ្ឌតម្រូវនៃការបិទ និងការស្តារបរិស្ថានឡើងវិញ និងលក្ខខណ្ឌតម្រូវនៃការគ្រប់គ្រង ដូចបានកំណត់នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដំបូង ឬពេញលេញ។

**មាត្រា១២៧** ._ ការឯកភាព

ក្នុងករណីដែលក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ឯកភាពលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ ឬកិច្ចសន្យាការពារបរិស្ថាន ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវចេញលិខិត និងវិញ្ញាបនបត្រឯកភាព សម្រាប់គម្រោងស្នើសុំនោះ ។

លិខិត និងវិញ្ញាបនបត្រឯកភាព ត្រូវមានលក្ខខណ្ឌតម្រូវ និងកាតព្វកិច្ចដែលត្រូវអនុវត្តគម្រោង រួមមាន ស្តង់ដារបញ្ចេញសារធាតុបំពុល វិធានការកាត់បន្ថយផលប៉ះពាល់ និងលក្ខខណ្ឌតម្រូវក្នុងការរៀបចំរបាយការណ៍ និងការអង្កេតតាមដាន ។

រាល់ការកែប្រែសកម្មភាពអភិវឌ្ឍន៍ខុសពីអ្វីដែលបានស្នើសុំនិងឯកភាព ត្រូវតែជូនដំណឹងនិងដាក់សំណើរកែប្រែ ជាបន្ទាន់ដល់ក្រសួងនិងស្ថាប័នទទួលបន្ទុកបរិស្ថាន។ ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានត្រូវពិនិត្យ ផ្តល់ការណែនាំ កែប្រែកិច្ចសន្យា លិខិត និងវិញ្ញាបនបត្រឯកភាពឬបើចាំបាច់ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាបណ្តុំ។

**មាត្រា១៣៧**._ ការពិនិត្យឯកសាវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងដែលមានស្រាប់ និងកំពុងដំណើរការ

មុនក្រមនេះចូលជាធរមាន ម្ចាស់គម្រោងដែលមានស្រាប់ និងកំពុងដំណើរការ ត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ និងកិច្ចសន្យាការពារបរិស្ថាន ស្របតាមលិខិតបទដ្ឋានគតិយុត្តដែលកំណត់ដោយក្រសួង ស្ថាប័ទទួលបន្ទុកបរិស្ថាន ដូចមានចែងក្នុងមាត្រា១៣៦ នៃក្រមនេះ ។

| | |
|---|---|
| | ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវពិនិត្យ ផ្តល់យោបល់ និងធ្វើសេចក្តីសម្រេចលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញ និងកិច្ចសន្យាការពារបរិស្ថាន ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។ |
| | មិនចាំបាច់រៀបរាប់បន្ថែមទេ មាននៅក្នុងការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រខាងលើរួចហើយ<br>សំណូមពរលុបចោល។<br>~~**មាត្រា១៤៤** ._ ការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ~~<br>~~ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ ត្រូវពិនិត្យ ពិចារណា និងដាក់បញ្ចូលនូវការវាយតម្លៃបរិស្ថានជាយុទ្ធសាស្ត្រ ដែលទាក់ទងនឹងវិស័យដែលពាក់ព័ន្ធនឹងសំណើគម្រោង ឬពាក់ព័ន្ធទៅនឹងដី ឬតំបន់ ដែលគម្រោងស្នើសុំនោះស្ថិតនៅ ។~~ |
| | **មាត្រា១៥០** ._ ការកែសម្រួលផែនការគ្រប់គ្រងបរិស្ថាន<br>ផែនការគ្រប់គ្រងបរិស្ថានដែលកែសម្រួលរួច ត្រូវទទួលការឯកភាពពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។<br>~~ការកំណត់ពេលវេលាក្នុងការកែសម្រួល ឬការកែលម្អ ផែនការគ្រប់គ្រងបរិស្ថាន ត្រូវធ្វើឡើងដោយមានការព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងម្ចាស់ គម្រោង។~~<br>ផែនការគ្រប់គ្រងបរិស្ថាន ត្រូវយកមកពិនិត្យនិងពិភាក្សាកែលម្អរជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានរៀងរាល់៣ឆ្នាំម្តង។ |

# <u>មតិយោបល់របស់អង្គការសង្គមស៊ីវិល</u>

## <u>លើសេចក្តីព្រាងទី១០នៃ ក្រមបរិស្ថាន និង ធនធានធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា</u>

## ប្រធានបទ៖ ការប្រែប្រួលអាកាសធាតុ និង ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ

| លរ NO | គន្លី/មាតិកា/ជំពូក **Book/Title (Copy and Paste from Environment Code)** | មតិយោបល់របស់សង្គមស៊ីវិល លើពង្រាងទី ៩.១ | សំណូមពរ/កំណែប្រែថ្មី លើពង្រាងទី ១០ ( CSO Suggestions ) |
|---|---|---|---|
| | **មាត្រា១៥២** ._ តួនាទី និងការទទួលខុសត្រូវ<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពត្រូវ ដឹកនាំការចរចាអំពីការប្រែប្រួលអាកាសធាតុជា លក្ខណៈអន្តរជាតិ ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស តាមរយៈអគ្គលេខាធិការដ្ឋានរបស់ខ្លួន និង ពាក់ព័ន្ធដទៃទៀត ទៅដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើរតួនាទីជាអង្គភាពបង្គោល ជាមួយអ្នកពាក់ព័ន្ធដទៃទៀតអំពីគោលនយោបាយ និងការរៀបចំកម្មវិធីស្តីពីការប្រែប្រួលអាកាសធាតុ និងផ្តល់អនុសាសន៍អំពីវិធានការជាគោលនយោបាយជូនរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។ | **មាត្រា១៥២** ._ តួនាទី និងការទទួលខុសត្រូវ<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពត្រូវ ដឹកនាំការចរចាអំពីការប្រែប្រួលអាកាសធាតុជា លក្ខណៈអន្តរជាតិ ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស តាមរយៈអគ្គលេខាធិការដ្ឋានរបស់ខ្លួន និង ពាក់ព័ន្ធដទៃទៀត ទៅដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើរតួនាទីជាអង្គភាពបង្គោល ជាមួយអ្នកពាក់ព័ន្ធដទៃទៀតអំពីគោលនយោបាយ និងការរៀបចំ <u>គ្រប់គ្រងការអនុវត្តកម្មវិធីថ្នាក់ជាតិ តាមដាន និងវាយតម្លៃ និង គ្រប់គ្រងចំណេះដឹង</u>ស្តីពីការប្រែប្រួលអាកាសធាតុ និងផ្តល់អនុសាសន៍អំពីវិធានការជាគោលនយោបាយជូនរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។ | បានទទួលយកក្នុងដោយប្តូរទៅមាត្រាទី ១៧៥ ភារកិច្ចនិងតួនាទីរបស់ស្ថាប័នទទួលខុសត្រូវ |

| | | | |
|---|---|---|---|
| | **មាត្រា១៥៣** ._ ផែការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ<br>ដោយអនុលោមតាមបទបញ្ញត្តស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថានក្នុងគន្ថីទី១ មាតិកាទី២ និងមាតិកាទី៣នៃក្រមនេះ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពត្រូវបង្កើត ធ្វើបច្ចុប្បន្នភាព និងសម្រប សម្រួលផែនការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុរយៈពេលវែង ដោយដោះស្រាយអំពីការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ការបន្សាំ ហិរញ្ញវត្ថុ ការអភិវឌ្ឍ និងការផ្ទេរបច្ចេកវិជ្ជា និងការកសាងសមត្ថភាព ស្របតាមគោលនយោបាយជាតិពាក់ព័ន្ធស្តីពីការប្រែប្រួលអាកាសធាតុ និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី ។ | **មាត្រា១៥៣** ._ ផែការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុថ្នាក់ជាតិ<br>ដោយអនុលោមតាមបទបញ្ញត្តស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថានក្នុងគន្ថីទី១ មាតិកាទី២ និងមាតិកាទី៣នៃក្រមនេះ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពត្រូវបង្កើត ធ្វើបច្ចុប្បន្នភាព និងសម្រប សម្រួលផែនការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុរយៈពេលវែង ស្របតាមគោលនយោបាយជាតិពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងកិច្ចព្រមព្រៀងអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខី ។ | ............ស្នើសុំបញ្ចូលពាក្យ នៅត្រង់ឃ្លាដែលបញ្ជាក់ពីដៃគូពាក់ព័ន្ធ ទាំងអស់ រួម<u>ទាំងវិស័យឯកជន</u> ដោយសារពួកគាត់គឺជាកំលាំងចលករ និងអង្គពាក់ព័ន្ធមួយយ៉ាងសំខាន់។ ទាំងនៅក្នុងការរៀបចំផែនការ និង អនុវត្តដោយមានការមួយចំនួនធំដើម្បីអោយមាននិរន្តរភាព ចំបាច់ត្រូវផ្សាភ្ជាប់វិស័យឯកជន ទាំងនៅថ្នាក់ជាតិ និងជាពិសេសនៅថ្នាក់ក្រោមជាតិ។ |
| | **មាត្រា១៥៧** ._ ផែនការ និងយុទ្ធសាស្ត្រឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ<br>អជ្ញាធរថ្នាក់ក្រោមជាតិទាំងអស់ត្រូវរចនា និងអនុវត្តផែនការ និងយុទ្ធសាស្ត្រ | **មាត្រា១៥៧** ._ ផែនការ និងយុទ្ធសាស្ត្រឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ អជ្ញាធរថ្នាក់ក្រោមជាតិទាំងអស់ត្រូវ | បានទទួលយកក្នុងមាត្រាទី ១៧៩ ផែនការ និងយុទ្ធសាស្ត្រឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ |

| | | | |
|---|---|---|---|
| | ក្នុងការឆ្លើយ តបចំពោះការប្រែប្រួលអាកាសធាតុ ស្របតាមគោលនយោបាយជាតិស្តីពីការប្រែប្រួលអាកាសធាតុពាក់ព័ន្ធ ដោយសហការជាមួយមន្ទីរខេត្តនៃក្រសួង និងស្ថាប័នពាក់ព័ន្ធ ។ | រៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពក្នុងការឆ្លើយ តបចំពោះការប្រែប្រួលអាកាសធាតុ ស្របតាមគោលនយោបាយជាតិស្តីពីការប្រែប្រួលអាកាសធាតុពាក់ព័ន្ធ ដោយសហការជាមួយមន្ទីរខេត្តនៃក្រសួង និងស្ថាប័នពាក់ព័ន្ធ ។ | |
| | **មាត្រា១៥៩** ._ ការសម្របសម្រួលកិច្ចសហការ និងការបង្កើតភាពជាដៃគូ<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពត្រូវ៖<br>ក- សម្របសម្រួលកិច្ចសហការជាលក្ខណ:អន្តរក្រសួង និងការចូលរួមរបស់អជ្ញាធរថ្នាក់ក្រោមជាតិក្នុងការរចនា និងការអនុវត្តសកម្មភាពការប្រែប្រួលអាកាសធាតុ រួមមាននូវការផ្តល់យន្តការសម្រាប់ការសម្រេចចិត្តផ្នែកបច្ចេកទេសជាលក្ខណ:អន្តរក្រសួងជាអាទិ៍ ។<br>ខ- បង្កើតភាពជាដៃគូ និងអនុស្សារណ:យោគយល់សម្រាប់ការអនុវត្ត និងបង្កើន ការឆ្លើយតប | **មាត្រា១៥៩** ._ ការសម្របសម្រួលកិច្ចសហការ និងការបង្កើតភាពជាដៃគូ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពត្រូវ៖<br>ក- សម្របសម្រួលកិច្ចសហការជាលក្ខណ:អន្តរក្រសួង និងការចូលរួមរបស់អជ្ញាធរថ្នាក់ក្រោមជាតិក្នុងការរៀបចំ និងការអនុវត្តសកម្មភាពការប្រែប្រួលអាកាសធាតុ រួមមាននូវការផ្តល់យន្តការសម្រាប់ការសម្រេចចិត្តផ្នែកបច្ចេកទេសជាលក្ខណ:អន្តរក្រសួងជាអាទិ៍ ។<br>ខ- បង្កើតភាពជាដៃគូ និងអនុស្សារណ:យោគយល់សម្រាប់ការអនុវត្ត និងបង្កើន ការឆ្លើយតប និងកិច្ចអន្តរាគមន៍នៃការប្រែប្រួលអាកាសធាតុ រវាងរដ្ឋាភិបាល អង្គភាពមិនមែនរដ្ឋាភិបាលនិងដៃគូរអភិវឌ្ឍន៍នានា រួមមានសកម្មភាពនៃការកាត់បន្ថយសមស្របជាលក្ខណ:ជាតិ។ | បានទទួលយកក្នុងមាត្រាទី១៨១<br>ស្នើសុំបន្ថែម<br>២-............................ចំពោះការប្រែប្រួលអាកាសធាតុ រវាងក្រសួងស្ថាប័នមាន សមត្ថកិច្ច និងអ្នកពាក់ព័ន្ធសាធារណៈ។ |

| | | | |
|---|---|---|---|
| | និងកិច្ចអន្តរាគមន៍នៃការប្រែប្រួលអាកាសធាតុរវាងរដ្ឋាភិបាល និងអង្គភាព មិនមែន រដ្ឋាភិបាល រួមមានសកម្មភាពនៃការកាត់បន្ថយសមស្របជាលក្ខណៈជាតិជាអាទិ៍ ។ | | |
| | **មាត្រា១៦០ ._** ការប្រែប្រួលអាកាសធាតុក្នុងសកម្មភាពអនុវត្ត<br>ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវរួមបញ្ចូលនូវការពិចារណាអំពីការប្រែប្រួលអាកាសធាតុទៅក្នុងការរចនានូវរាល់សកម្មភាពអនុវត្តទាំងអស់ និងពិចារណាទៅលើផលប៉ះពាល់នៃសកម្មភាពនោះ ទៅលើការបំភាយឧស្មន័ផ្ទះកញ្ចក់ ការប្រឈមទៅនឹងហានិភ័យអាកាសធាតុ និងសមត្ថភាពបន្សាំ ។<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពត្រូវផ្តល់ដំបូន្មានផ្នែកបច្ចេកទេសទៅកាន់ក្រសួង ស្ថាប័នពាក់ព័ន្ធទៅលើការរចនានូវសកម្មភាពអនុវត្តន៍ រួមមានវិធានការណ៍ បច្ចេកទេស និង ដំណើរការ ឆ្លើយ | **មាត្រា១៦០ ._** ការប្រែប្រួលអាកាសធាតុក្នុងសកម្មភាពអនុវត្ត<br>ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវរួមបញ្ចូលនូវការពិចារណាអំពីការប្រែប្រួលអាកាសធាតុទៅក្នុងការកំណត់នូវរាល់សកម្មភាពអនុវត្តទាំងអស់ និងពិចារណាទៅលើផលប៉ះពាល់នៃសកម្មភាពនោះ ដែលនាំទៅរក ការប្រឈមទៅនឹងហានិភ័យអាកាសធាតុ ជាពិសេសសមត្ថភាពបន្សាំ ។<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពត្រូវផ្តល់ដំបូន្មានផ្នែកបច្ចេកទេសទៅកាន់ក្រសួង ស្ថាប័នពាក់ព័ន្ធទៅលើការកំណត់នូវសកម្មភាពអនុវត្តន៍ រួមមានវិធានការណ៍ បច្ចេកទេស និង ដំណើរការ ឆ្លើយតបទៅ តាមផ្នែកជាក់លាក់មួយៗជាអាទិ៍ ។ | សូមពិនិត្យមតិយោបល់របស់សង្គមស៊ីវិលលើសេចក្តីព្រាងទី៩.១ |

| | | | |
|---|---|---|---|
| | តបទៅលើការសាកល្បងតាមផ្នែកជាក់លាក់មួយៗជាអាទិ៍ ។ | | |
| | **មាត្រា១៦១ ._** ការប្រែប្រួលអាកាសធាតុក្នុងការធ្វើការសម្រេចចិត្ត<br>ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវធានាថាត្រូវធ្វើការពិចារណាអំពីការប្រែប្រួលអាកាសធាតុក្នុងដំណើការធ្វើការសម្រេចចិត្តពាក់ព័ន្ធទាំងអស់ទាក់ទិននឹងការអនុវត្តសកម្មភាពក្រោមសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នទាំងនោះ ។ | **មាត្រា១៦១ ._** ការប្រែប្រួលអាកាសធាតុក្នុងការធ្វើការសម្រេចចិត្ត<br>ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវធ្វើការពិចារណាអំពីការប្រែប្រួលអាកាសធាតុក្នុងដំណើការធ្វើការសម្រេចចិត្តពាក់ព័ន្ធទាំងអស់ទាក់ទិននឹងការអនុវត្តសកម្មភាពក្រោមសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នទាំងនោះ ។ | បានទទួលយកក្នុងមាត្រាទី១៨២ |
| | **មាត្រា១៦៤ ._** ក្របខ័ណ្ឌអង្កេតតាមដាន និងវាយតម្លៃតាមវិស័យ<br>ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវបង្កើត និងគ្រប់គ្រងនូវក្របខ័ណ្ឌអង្កេតតាមដាន និងវាយតម្លៃការប្រែប្រួលបរិស្ថានតាមវិស័យដើម្បីតាមដានប្រសិទ្ធភាពនៃការឆ្លើយតបវិធានការណ៍ដែលដាក់ចេញក្នុងផែនការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុតាមវិស័យពាក់ព័ន្ធ ដោយមានការគាំទ្រពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយ | **មាត្រា១៦៤ ._** ក្របខ័ណ្ឌអង្កេតតាមដាន និងវាយតម្លៃតាមវិស័យ<br>ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវបង្កើត និងគ្រប់គ្រងនូវក្របខ័ណ្ឌអង្កេតតាមដាន និងវាយតម្លៃការប្រែប្រួលអាកាសធាតុតាមវិស័យដើម្បីតាមដានប្រសិទ្ធភាពនៃការឆ្លើយតបនឹងវិធានការណ៍ដែលដាក់ចេញក្នុងផែនការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុតាមវិស័យពាក់ព័ន្ធ ដោយមានការគាំទ្រពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | បានទទួលយកក្នុង មាត្រាទី១៨៥.ក្របខ័ណ្ឌអង្កេតតាមដាន និងការវាយតម្លៃថ្នាក់ជាតិ |

| | | | |
|---|---|---|---|
| | ចីរភាព និងធ្វើរបាយការណ៍ជាទៀងទាត់ទៅកាន់ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ។ ក្របខ័ណ្ឌនេះត្រូវធ្វើឡើងស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដែលចេញដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ។ | និងធ្វើរបាយការណ៍ជាទៀងទាត់ទៅកាន់ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ។ ក្របខ័ណ្ឌនេះត្រូវធ្វើឡើងស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដែលចេញដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ។ | |
| | **មាត្រា១៦៦** ._ សកម្មភាពអង្កេតតាមដាន និងវាយតម្លៃ<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវសម្របសម្រួល និងសកម្មភាពអង្កេតតាមដាន និងវាយតម្លៃដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។<br>ក្រសួង និងស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវសកម្មភាពអង្កេតតាមដាន និងវាយតម្លៃដែលតម្រូវទាំងអស់ ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធនៃមាតិកានេះ ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។<br>អជ្ញាធរថ្នាក់ក្រោមជាតិទាំងអស់ ត្រូវធ្វើសកម្មភាពអង្កេតតាមដាន និងវាយតម្លៃ ស្របតាម ក្របខ័ណ្ឌ និងលិខិត | **មាត្រា១៦៦** ._ សកម្មភាពអង្កេតតាមដាន និងវាយតម្លៃ<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវសម្របសម្រួល និងធ្វើសកម្មភាពអង្កេតតាមដាន និងវាយតម្លៃដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។<br>ក្រសួង និងស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវធ្វើសកម្មភាពអង្កេតតាមដាន និងវាយតម្លៃដែលតម្រូវទាំងអស់ ស្របតាមបទប្បញ្ញត្តិពាក់ព័ន្ធនៃមាតិកានេះ ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។<br>អជ្ញាធរថ្នាក់ក្រោមជាតិទាំងអស់ ត្រូវធ្វើសកម្មភាពអង្កេតតាមដាន និងវាយតម្លៃ ស្របតាម ក្របខ័ណ្ឌ និងលិខិតបទដ្ឋានគតិយុត្តស្តីពី | បានទទួលយកក្នុងមាត្រា១៨៦ នៃពង្រាងទី១០<br><br>ស្នើបន្ថែម៖ ក្នុងសកម្មភាពតាមដាននិងវាយតម្លៃ គួរមានការចូលរួមពីសង្គមស៊ីវិល និង វិស័យឯកជន។ |

| | | | |
|---|---|---|---|
| | បទដ្ឋានគតិយុត្តស្តីពីការអង្កេតតាមដាននិងការវាយតម្លៃតាមវិស័យ ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងដោយសហការជាមួយមន្ទីរខេត្តនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ។ | ការអង្កេតតាមដាននិងការវាយតម្លៃតាមវិស័យ ស្របតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងដោយសហការជាមួយមន្ទីរខេត្តនៃក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ។ | |
| | **មាត្រា១៦៧** ._ ការរៀបចំរបាយការណ៍ស្តីពីការអង្កេតតាមដាន និងការវាយតម្លៃ<br>រាល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវរាយការណ៍ឲ្យទាន់ពេលវេលាទៅកាន់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពស្តីពីសូចនករពាក់ពន្ធ័នៃក្របខ័ណ្ឌអង្កេតតាមដាន និងវាយតម្លៃថ្នាក់ជាតិ លិខិតបទដ្ឋានគតិយុត្តស្តីពីការអង្កេតតាមដាន និងវាយតម្លៃដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដទៃទៀត និងស្តីពីក្របខ័ណ្ឌស្តីពីការអង្កេតតាមដាននិងការវាយតម្លៃ តាមវិស័យ ស្របជាមួយនឹងលិខិតបទដ្ឋានគតិយុត្ត។ របាយការណ៍នេះ ត្រូវដាក់ឲ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទបញ្ញត្តស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថា | **មាត្រា១៦៧** ._ ការរៀបចំរបាយការណ៍ស្តីពីការអង្កេតតាមដាន និងការវាយតម្លៃ<br>រាល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវរាយការណ៍ឲ្យទាន់ពេលវេលាទៅកាន់ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពស្តីពីបច្ចុប្បន្នភាពដែលសមស្របទៅនឹងសូចនករពាក់ពន្ធ័នៃក្របខ័ណ្ឌអង្កេតតាមដាន និងវាយតម្លៃថ្នាក់ជាតិ លិខិតបទដ្ឋានគតិយុត្តស្តីពីការអង្កេតតាមដាន និងវាយតម្លៃដែលពាក់ព័ន្ធ នឹងការប្រែប្រួលអាកាសធាតុដទៃទៀត និងស្តីពីក្របខ័ណ្ឌស្តីពីការអង្កេតតាមដាននិងការវាយតម្លៃ តាមវិស័យ ស្របជាមួយនឹងលិខិតបទដ្ឋានគតិយុត្ត។ របាយការណ៍នេះ ត្រូវដាក់ឲ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទបញ្ញត្តស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថា | មាត្រាទី ១៨៧ ក្នុងពង្រាងទី១០ មិនទាន់ទទួលយកមតិយោបល់ |

| | | | |
|---|---|---|---|
| | ន ដែលមានចែងក្នុងគន្លីទី១ មាតិកាទី២ និងមាតិកាទី៣ នៃក្រមនេះ ។ | ន ដែលមានចែងក្នុងគន្លីទី១ មាតិកាទី២ និង មាតិកាទី៣ នៃក្រមនេះ ។ | |
| | **មាត្រា១៦៨**._ការរៀបចំរបាយការណ៍ជាអន្តរជាតិ<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវរាយការណ៍ទៅកាន់អង្គការអន្តរជាតិស្តីពីការ អនុវត្តរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងការឆ្លើយតបទៅលើការប្រែប្រួលអាកាសធាតុ រួមមានការប្រព្រឹត្តស្របតាមកិច្ចព្រមព្រៀងអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខីជាអាទ៍។ | **មាត្រា១៦៨**._ការរៀបចំរបាយការណ៍ជាអន្តរជាតិ<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវរាយការណ៍ទៅកាន់អង្គការសហប្រជាជាតិស្តីពីការអនុវត្តរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងការឆ្លើយតបទៅលើការប្រែប្រួលអាកាសធាតុ រួមមានការប្រព្រឹត្តស្របតាមកិច្ចព្រមព្រៀងអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដែលព្រះរាជាណាចក្រកម្ពុជាជាភាគីហត្ថលេខីជាអាទ៍។ | មាត្រាទី ១៨៨ ក្នុងពង្រាងទី១០<br>មិនទាន់ទទួលយកមតិយោបល់ |
| | **មាត្រា១៧១** . _ព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវដើម្បីប្រមូល ធ្វើបច្ចុប្បន្នភាព គ្រប់គ្រង និងដាក់ឲ្យសាធារណជនអាចស្វែងរកបានបាននូវព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុទាំងឡាយដែលពាក់ព័ន្ធ | **មាត្រា១៧១** . _ព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវ~~ដើម្បី~~ ប្រមូល ធ្វើបច្ចុប្បន្នភាព គ្រប់គ្រង និង ដាក់ឲ្យសាធារណជនអាចស្វែងរកបាន~~បាន~~នូវព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ ទាំងឡាយដែលពាក់ព័ន្ធទៅនឹង ការឆ្លើយតប | មាត្រាទី ១៩១ ក្នុងពង្រាងទី១០<br><br>ស្នើឱ្យពិនិត្យមតិយោបល់របស់សង្គមស៊ីវិលបន្ថែម លើពង្រាងទី ៩.១ |

| | | | |
|---|---|---|---|
| | ទៅនឹងការអនុវត្តការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះការប្រែប្រួលអាកាសធាតុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុករៀបចំផែនការ ក្រសួង ស្ថាប័នទទួលបន្ទុកស្ថិតិថ្នាក់ជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ស្របតាមបទបញ្ញត្តស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាន ក្នុងគន្លឹទី១ មាតិកាទី២ និងមាតិកាទី៣ នៃក្រមនេះ ។<br>ព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ មានជាអាទិ៍៖<br>ក-ការកំណត់ទីតាំងនៃហានិភ័យពាក់ព័ន្ធទៅនឹងអាកាសធាតុ សេណារីយ៉ូនៃ ការប្រែប្រួលអាកាសធាតុ និងការវាយតម្លៃភាពងាយរងគ្រោះ និងជម្រើស និងសមត្ថភាព ក្នុង ការបន្សាំ ។<br>ខ-កម្រិតនៃការបំភាយឧស្ម័នដោយសារការបំផ្លាញព្រៃឈើ និងកត្តានានាអំពីការ បំភាយ | ប្រកបដោយប្រសិទ្ធភាពចំពោះការប្រែប្រួលអាកាសធាតុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុករៀបចំផែនការ ក្រសួង ស្ថាប័នទទួលបន្ទុកស្ថិតិថ្នាក់ជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ស្របតាមបទបញ្ញត្តស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន ក្នុងគន្លឹទី១ មាតិកាទី២ និងមាតិកាទី៣ នៃក្រមនេះ ។<br>ព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ មានជាអាទិ៍៖<br>ក-ពតិមានគ្រោះហានិភ័យពាក់ព័ន្ធទៅនឹងអាកាសធាតុ សេណារីយ៉ូនៃការប្រែប្រួលអាកាសធាតុ និងការវាយតម្លៃភាពងាយរងគ្រោះ<br>ខ-ជម្រើស លទ្ធភាព និងសមត្ថភាព ក្នុងការបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ។<br>គ-កម្រិត ប្រភព និងកត្តានានាអំពីការបំភាយ ឧស្ម័នផ្ទះកញ្ចក់ តាមវិស័យ ជាពិសេស វិស័យថាមពល ព្រៃឈើ និងកសិកម្ម ។ | |

| | | | |
|---|---|---|---|
| | ឧស្ម័ន ដែលបានសន្មត ស្របតាម<br>លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ។<br>គ-ប្រភព និងការបំភាយ<br>ឧស្ម័នផ្ទះកញ្ចក់ ។<br>ឃ-ជម្រើសក្នុងការកាត់<br>បន្ថយឧស្ម័នផ្ទះកញ្ចក់ និងការលើក<br>កម្ពស់ភាពធន់ស៊ាំ ដែលមានជាតិ<br>កាបូនតិច ។<br>ង-ការកាត់បន្ថយការបំភាយ<br>ឧស្ម័នដែលមានការបញ្ជាក់ពីការ<br>ចូលរួមអនុវត្តរបស់ព្រះរាជាណា<br>ចក្រកម្ពុជានៅក្នុងយន្តការហិរញ្ញប្ប<br>ទានអាកាសធាតុដែលផ្អែកលើលទ្ធ<br>ផល ។<br>ច-ការកំណត់ទីតាំងនៃ<br>គម្រោង និងអន្តរគមន៍នានាដែល<br>ពាក់ព័ន្ធទៅនឹងការ កាត់<br>បន្ថយ និងការបន្សាំទៅនឹងការប្រែ<br>ប្រួលអាកាសធាតុ ដែលមាន<br>ប្រតិបត្តិការនៅក្នុង ព្រះរាជា<br>ណាចក្រកម្ពុជា រួមមាន ការពិនិត្យ | ង-ការកាត់បន្ថយការបំភាយ<br>ឧស្ម័នផ្ទះកញ្ចក់ដែលមានចែងនៅក្នុង<br>យន្តការហិរញ្ញប្បទានអាកាសធាតុ<br>ដែលផ្អែកលើលទ្ធផល ។<br>ច- គម្រោង និងអន្តរគមន៍នានា<br>ដែលពាក់ព័ន្ធទៅនឹងការ កាត់<br>បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួល<br>អាកាសធាតុ ដែលមានប្រតិបត្តិការនៅ<br>ក្នុង ព្រះរាជាណាចក្រកម្ពុជា រួមទាំង<br>ការពិនិត្យតាមដានហិរញ្ញប្បទាននានា<br>ដែលទទួលបានផងដែរ។<br>ឆ-ការអនុវត្តល្អក្នុងការកាត់<br>បន្ថយ និងការបន្សាំ ដែលស្របតាមប<br>រិបទនៃព្រះរាជាណាចក្រកម្ពុជា មានជា<br>អាទិ៍ ប្រសិទ្ធភាព ប្រសិទ្ធផល និងភាព<br>សន្សំសំចៃនៃការធ្វើអន្តរាគមន៍ និងមេ<br>រៀន ដែលបានយល់ដឹងពីគម្រោងនិង<br>អន្តរាគមន៍ ដែលបានអនុវត្តន៍នៅក្នុង<br>ព្រះរាជាណាចក្រកម្ពុជា រួមមាន ការ<br>សាកល្បង ឬការដកពិសោធន៍បច្ចេក<br>វិទ្យានានាក្នុងការកាត់បន្ថយការបំភាយ | |

| | | | |
|---|---|---|---|
| | តាមដានជំនួយក្រៅស្រុកដែលទទួលបានផងដែរ ជាអាទិ៍ ។<br>ឆ-ទម្លាប់នៃការកាត់បន្ថយ និងការបន្សុាំល្អបំផុត ដែលស្រប តាមបរិបទនៃព្រះរាជា ណាចក្រកម្ពុជា មានជាអាទិ៍ លទ្ធភាព និង ប្រសិទ្ធភាពតម្លៃនៃការធ្វើ អន្តរាគមន៍ និងមេរៀន ដែលបាន យល់ដឹងពីគម្រោង និងអន្តរាគមន៍ ដែលបានអនុវត្តន៍នៅក្នុងព្រះរាជាណាចក្រ កម្ពុជា រួមមាន ការ សាកល្បង ឬការដកពិសោធន៍ បច្ចេកវិជ្ជានានាក្នុងការកាត់បន្ថយ និងការ បន្សុាំថ្មីៗ ជាអាទិ៍។<br>ជ-ការរៀបចំរបាយការណ៍ ដែលបានពីឧបករណ៍អង្កេតតាមដាន និងវាយតម្លៃទៅលើការប្រែប្រួលអាកាសធាតុ ស្របតាម មាតិកានេះ ។ | ឧស្ម័នផ្ទះកញ្ចក់ និងការបន្សុាំថ្មីៗ ជាអាទិ៍។<br>ជ- របាយការណ៍ដែលបានពីឧបករណ៍អង្កេតតាមដាន និងវាយតម្លៃទៅលើការប្រែប្រួលអាកាសធាតុ ស្របតាមមាតិកានេះ ។ | |

| | | | |
|---|---|---|---|
| | **មាត្រា១៧២** ._ កិច្ចសហការដើម្បីដាក់ព័ត៌មានអំពីការប្រែប្រួលអាកាសធាតុឲ្យសាធារណជនអាចស្វែងរកបាន<br>គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវរួមសហកាជាមួយក្រុម ប្រឹក្សាអភិវឌ្ឍន៍ដោយចីរភាព ដើម្បីប្រមូល ធ្វើបច្ចុប្បន្នភាព គ្រប់គ្រង និងដាក់ឲ្យសាធារណជន អាចប្រើប្រាស់បាននូវព័ត៌មានអំពីការប្រែប្រួលអាកាសធាតុទាំងឡាយទៅតាមវិស័យរបស់ខ្លួន ព្រមទាំងព័ត៌មានអំពីការអនុវត្តការធ្វើអន្តរាគមន៍ទៅលើការប្រែប្រួលអាកាសធាតុ រួមមានលទ្ធផលទាំងឡាយនៃសូចនករអង្កេតតាមដាន និងវាយតម្លៃដែលពាក់ព័ន្ធ និងមេរៀនដែលបាន យល់ដឹងពីការអនុវត្តសកម្មភាពសាកល្បងនានា ជាអាទិ៍ ។ ព័ត៌មាននេះត្រូវដាក់ឲ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថា | **មាត្រា១៧២** ._ កិច្ចសហការដើម្បីដាក់ព័ត៌មានអំពីការប្រែប្រួលអាកាសធាតុឲ្យសាធារណជនអាចស្វែងរកបាន<br>គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវរួមសហកាជាមួយក្រុម ប្រឹក្សាអភិវឌ្ឍន៍ដោយចីរភាព ដើម្បីប្រមូល ធ្វើបច្ចុប្បន្នភាព គ្រប់គ្រង និងដាក់ឲ្យសាធារណជន អាចប្រើប្រាស់បាននូវព័ត៌មានអំពីការប្រែប្រួលអាកាសធាតុទាំងឡាយទៅតាមវិស័យរបស់ខ្លួន ព្រមទាំងព័ត៌មានអំពីការអនុវត្តការធ្វើអន្តរាគមន៍ទៅលើការប្រែប្រួលអាកាសធាតុ រួមមានលទ្ធផលទាំងឡាយដោយផ្អែកលើសូចនករអង្កេតតាមដាន និងវាយតម្លៃដែលពាក់ព័ន្ធ និងមេរៀនដែលបាន យល់ដឹងពីការអនុវត្តសកម្មភាពនានា ជាអាទិ៍ ។ ព័ត៌មាននេះត្រូវដាក់ឲ្យសាធារណជនអាចស្វែងរកបាន ស្របតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថានក្នុងគន្ថីទី១ មាតិកាទី២ និងមាតិកាទី៣ នៃក្រមនេះ ។ | មាត្រាទី ១៩៦ ប្រព័ន្ធព័ត៌មានដែលសាធារណៈជនអាចស្វែងរកបាន<br>ស្នើឱ្យពិនិត្យមតិយោបល់របស់សង្គមស៊ីវិលបន្ថែម លើសេចក្តីព្រាងទី ៩.១ |

| | | | |
|---|---|---|---|
| | នក្នុងគន្លឹទី១ មាតិកាទី២ និងមាតិកាទី៣ នៃក្រមនេះ ។ | | |
| | **មាត្រា១៧៦** . _ ប្រព័ន្ធទទួលបានព័ត៌មានជាសាធារណៈ<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវបង្កើត និងគ្រប់គ្រងប្រព័ន្ធទទួលបានព័ត៌មានជាសាធារណៈ ដើម្បីបង្រួមបង្រួមព័ត៌មានទាំងអស់អំពីការប្រែប្រួលអាកាសធាតុដែលផលិតដោយ រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ ។ ប្រព័ន្ធនេះ ត្រូវបង្កើតឡើង ស្របតាមបទបញ្ញត្តស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថានក្នុងគន្លឹទី១ មាតិកាទី២ និងមាតិកាទី៣ នៃក្រមនេះ ។<br>គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធទាំងអស់ ត្រូវរួមសហការជាមួយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព បង្កើត និងធ្វើបច្ចុប្បន្នភាពជាប្រចាំទៅលើប្រព័ន្ធ ព័ត៌មាននេះ ស្របតាមលិខិត | **មាត្រា១៧៦** . _ ប្រព័ន្ធទទួលបានព័ត៌មានជាសាធារណៈ<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវបង្កើត និងគ្រប់គ្រងប្រព័ន្ធទទួលបានព័ត៌មានជាសាធារណៈ ដើម្បីបប្រមែប្រមូលព័ត៌មានទាំងអស់អំពីការប្រែប្រួលអាកាសធាតុដែលផលិតដោយ រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ ។ ប្រព័ន្ធនេះ ត្រូវបង្កើតឡើង ស្របតាមបទបញ្ញត្តស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថានក្នុងគន្លឹទី១ មាតិកាទី២ និងមាតិកាទី៣ នៃក្រមនេះ ។<br>គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធទាំងអស់ ត្រូវរួមសហការជាមួយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព បង្កើត និងធ្វើបច្ចុប្បន្នភាពពតិមានជាប្រចាំទៅលើប្រព័ន្ធព័ត៌មាននេះ ស្របតាមលិខិតបទដ្ឋានគតិយុត្ត | ប្តូរទៅមាត្រា ១៩១<br>សំណូមពរៈ ការប្រមូលពតិមានអាកាសធាតុ គឺធ្វើឡើយដោយមានលក្ខណះវិទ្យាសាស្រ្ត និងទុកចិត្តបាន ដូចជា (ការវាយតំលៃកាត់បន្ថយភាពងាយរងគ្រោះ VRA) ដែលមានចូលរួម និងការរៀបចំផែនការបន្សាំ និងការកាត់បន្ថយហេតុ ពីមូលដ្ឋាន |

| | | | |
|---|---|---|---|
| | បទដ្ឋានគតិយុត្តពាក់ព័ន្ធ ដែលចេញដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ។ | ពាក់ព័ន្ធ ដែលចេញដោយក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ។ | |
| | **មាត្រា១៨៥ .**_ ការពង្រឹងសមត្ថភាពស្ថាប័ន និងសមត្ថភាពបុគ្គល<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្នុងកិច្ចសហប្រតិបត្តិការជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវពង្រឹងបរិយាកាសអំណោយផលរបស់ព្រះរាជាណាចក្រកម្ពុជា សមត្ថភាពស្ថាប័ន និងសមត្ថភាពបុគ្គលដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ ។ | **មាត្រា១៨៥ .**_ ការពង្រឹងសមត្ថភាពស្ថាប័ន និងសមត្ថភាពបុគ្គល<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្នុងកិច្ចសហប្រតិបត្តិការជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវពង្រឹងបរិយាកាសអំណោយផល សម្រាប់កសាង និងពង្រឹងសមត្ថភាពស្ថាប័ន និងសមត្ថភាពបុគ្គលដើម្បីដោះស្រាយបញ្ហានៃការប្រែប្រួលអាកាសធាតុ ។ | សូមពិនិត្យមតិយោបល់លើពង្រាងទី៩.១ |
| | **មាត្រា១៨៨ .**_ យន្តការកសាងចំណេះដឹង និងលើកកម្ពស់ការស្រាវជ្រាវ<br>ដោយសហការជាមួយនឹងអ្នកពាក់ព័ន្ធទាំងអស់ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវធ្វើការពង្រឹង និងបង្កើតយន្តការផ្សេងៗក្នុងការកសាងចំណេះដឹង និងលើកកម្ពស់ ការស្រាវជ្រាវស្តីពីការ | **មាត្រា១៨៨ .**_ យន្តការកសាងចំណេះដឹង និងលើកកម្ពស់ការស្រាវជ្រាវ<br>ដោយសហការជាមួយនឹងអ្នកពាក់ព័ន្ធទាំងអស់ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ ដោយចីរភាព ត្រូវធ្វើការពង្រឹង និងបង្កើតយន្តការផ្សេងៗក្នុងការកសាងចំណេះដឹង និងលើកកម្ពស់ ការស្រាវជ្រាវស្តីពីការអនុវត្ត និងបច្ចេកវិទ្យានៃការ | សូមពិនិត្យមតិយោបល់លើពង្រាងទី៩.១ |

| | | | |
|---|---|---|---|
| | អនុវត្ត និងបច្ចេកវិជ្ជានៃការកាត់បន្ថយ និងការបន្សាំការប្រែប្រួលអាកាសធាតុ ។ | កាត់បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ។ | |
| | **មាត្រា១៨៩ .**_ ការអភិវឌ្ឍក្របខ័ណ្ឌហិរញ្ញប្បទាន<br>ដោយសហការជាមួយនឹងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវបង្កើត និងគ្រប់គ្រងក្របខ័ណ្ឌហិរញ្ញប្បទាន សម្រាប់ សកម្មភាពនានានៃការប្រែប្រួលអាកាសធាតុ ។ ក្របខ័ណ្ឌបែបនេះ ត្រូវរួមបញ្ចូលនូវការវិភាគ អំពីតម្រូវការហិរញ្ញប្បទាន យុទ្ធសាស្ត្រក្នុងការបំពេញនូវសេចក្តីត្រូវការទាំងនេះតាមរយៈការប្រើប្រាស់ប្រភពហិរញ្ញវត្ថុក្នុងស្រុក និងក្រៅស្រុកដែលមានស្រាប់ ក៏ដូចជាវិធានការនៃការអភិវឌ្ឍសមត្ថភាពណាមួយ យន្តការហិរញ្ញវត្ថុ ឬកំណែទម្រង់ស្ថាប័ននានា ដើម្បីធ្វើការកៀងគរ និងគ្រប់គ្រងហិរញ្ញវត្ថុ ផ្នែកប្រែប្រួលអាកាសធាតុក្នុងលក្ខណៈដែលមានប្រសិទ្ធផលដ៏ខ្ពស់បំផុតមួយ ។ | **មាត្រា១៨៩ .**_ ការអភិវឌ្ឍក្របខ័ណ្ឌហិរញ្ញប្បទាន<br>ដោយសហការជាមួយនឹងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវបង្កើត និងគ្រប់គ្រងក្របខ័ណ្ឌហិរញ្ញប្បទាន សម្រាប់សកម្មភាពនានានៃការប្រែប្រួលអាកាសធាតុ ។ ក្របខ័ណ្ឌបែបនេះ ត្រូវរួមបញ្ចូលនូវការវិភាគអំពីតម្រូវការហិរញ្ញប្បទាន យុទ្ធសាស្ត្រក្នុងការបំពេញនូវសេចក្តីត្រូវការទាំងនេះតាមរយៈការកៀងគរ និងប្រើប្រាស់ប្រភពហិរញ្ញវត្ថុក្នុងស្រុក និងក្រៅស្រុកដែលមានស្រាប់ សំដៅធ្វើយ៉ាងណាអោយមានប្រសិទ្ធភាព និងប្រសិទ្ធផលខ្ពស់។ ក្របខ័ណ្ឌបែបនេះនឹងត្រូវបង្កើតឡើង ដោយអនុលោមទៅតាមបទបញ្ញត្តផ្សេងៗស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មាន ក្នុងគន្លឹះទី១ មាតិកាទី២ និងមាតិកាទី៣ នៃក្រមនេះ ។ | ប្តូរទៅ ២០៣ និង១៨៤<br>ទទួលយកបាន |

| | | | |
|---|---|---|---|
| | ក្របខ័ណ្ឌបែបនេះនឹងត្រូវបង្កើតឡើង ដោយអនុលោមទៅតាមបទបញ្ញត្តផ្សេងៗស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថាន ក្នុងគន្លីទី១ មាតិកាទី២ និងមាតិកាទី៣ នៃក្រមនេះ ។ | | |
| | **មាត្រា១៩១** ._ ការប្រែប្រួលអាកាសធាតុនៅក្នុងថវិកាជាតិ<br>ដោយមានការគាំទ្របច្ចេកទេសពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវពិចារណាពីផលប៉ះពាល់ និងដំណោះស្រាយផ្សេងៗនៃការប្រែប្រួលអាកាសធាតុនៅក្នុងដំណើរការថវិកាជាតិ ។ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវផ្តល់ឲ្យក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវការវិភាគប្រចាំឆ្នាំអំពីហានិភ័យ និងអាទិភាពនៃការប្រែប្រួលអាកាសធាតុ ។<br>ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងហិរញ្ញវត្ថុ ត្រូវពិចារណា និងបញ្ចូល នូវការវិភាគនេះនៅ | មាត្រា១៩១ ._ ការបែងចែកថវិកាជាតិសម្រាប់ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ<br>ដោយមានការគាំទ្របច្ចេកទេសពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវពិចារណាពីផលប៉ះពាល់ និងដំណោះស្រាយផ្សេងៗនៃការប្រែប្រួល អាកាសធាតុនៅក្នុងដំណើរការថវិកាជាតិ ។ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវផ្តល់ឲ្យក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវការវិភាគប្រចាំឆ្នាំអំពីហានិភ័យ និងអាទិភាពក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ។ ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងហិរញ្ញវត្ថុ ត្រូវពិចារណា និងបញ្ចូល នូវការវិភាគនេះនៅក្នុងសារាចរស្តីពីការរៀបចំថវិកាប្រចាំឆ្នាំ និងបញ្ចូលការណែនាំអំពីការ | ប្តូរទៅ២០៦<br>ទទួលយកបាន ប៉ុន្តែស្នើរសុំអោយមានកញ្ចប់ថវិការ ដាច់ដោយឡែកដែលវិភាធន៍ពីថវិការជាតិ សំរាប់សកម្មភាព DRR/CCA នៅតាមមូលដ្ឋានសហគមន៍ |

| | | | |
|---|---|---|---|
| | ក្នុងសារាចរស្តីពីការរៀបចំថវិកាប្រចាំឆ្នាំ និងបញ្ចូលការណែនាំអំពីការដាក់បញ្ចូលផលប៉ះពាល់ និងដំណោះស្រាយផ្សេងៗនៃការប្រែប្រួលអាកាសធាតុ ទៅក្នុងលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធី សម្រាប់ថវិកាគម្រោង ។<br>ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវតាមដាន និងដាក់ឲ្យសាធារណជនអាចស្វែងរកបាននូវព័ត៌មានស្តីពីការបែងចែក ការចំណាយ និងប្រសិទ្ធិភាពនៃហិរញ្ញវត្ថុការប្រែប្រួលអាកាសធាតុតាមរយៈថវិកាជាតិ ។ | ដាក់បញ្ចូលផលប៉ះពាល់ និងដំណោះស្រាយផ្សេងៗនៃការប្រែប្រួលអាកាសធាតុ ទៅក្នុងលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធី សម្រាប់ថវិកាគម្រោង ។<br>ក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវតាមដាន និងដាក់ឲ្យសាធារណជនអាចស្វែងរកបាននូវព័ត៌មានស្តីពីការបែងចែក ការចំណាយ និងប្រសិទ្ធិភាពនៃហិរញ្ញវត្ថុការប្រែប្រួលអាកាសធាតុតាមរយៈថវិកាជាតិ ។ | |
| | **មាត្រា១៩២** ._ ផលប៉ះពាល់ និងដំណោះស្រាយនៃការប្រែប្រួលអាកាសធាតុនៅក្នុងការដាក់ស្នើថវិកា<br>គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអជ្ញាធរថ្នាក់ក្រោមជាតិទាំងអស់ ត្រូវដាក់បញ្ចូល នូវផលប៉ះពាល់ និងដំណោះស្រាយនៃការប្រែប្រួលអាកាសធាតុ នៅក្នុងការដាក់ស្នើថវិការបស់ខ្លួន ដោយអនុលោមទៅ | **មាត្រា១៩២** ._ ផលប៉ះពាល់ និងដំណោះស្រាយនៃការប្រែប្រួលអាកាសធាតុនៅក្នុងការដាក់ស្នើថវិកា<br>គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអជ្ញាធរថ្នាក់ក្រោមជាតិទាំងអស់ ត្រូវដាក់បញ្ចូល នូវកញ្ចប់ថវិកាសម្រាប់ការឆ្លើយតបទៅនឹងផលប៉ះពាល់ និងដំណោះស្រាយនៃការប្រែប្រួលអាកាសធាតុ នៅក្នុងគម្រោងសំណើថវិការបស់ខ្លួន ដោយអនុលោមទៅតាមលិខិតបទដ្ឋានគតិ | ប្តូរទៅ២០៧<br>មាត្រានេះអាចទទួលយកបាន គួរតែបន្ថែមការស្នើសុំថវិការទៅលើការអនុវត្តការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ |

| | | | |
|---|---|---|---|
| | តាមលិខិតបទដ្ឋានគតិយុត្តដែលបានចេញដោយក្រសួង ស្ថាប័នទទួលបន្ទុក សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ | យុត្តដែលបានចេញដោយក្រសួង ស្ថាប័នទទួលបន្ទុក សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ | |
| | **មាត្រា១៩៣ .**_ ការលើកកម្ពស់ការវិនិយោគលើអាកាសធាតុដែលមានលក្ខណៈឆ្លាតវៃ<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយនឹងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវធ្វើការពិគ្រោះយោបល់ជាមួយនឹងអ្នកពាក់ព័ន្ធទាំងអស់ អំពីវិធានការសារពើពន្ធជាសក្តានុពល បទប្បញ្ញត្តិ ស្តង់ដារនិងយន្តការដែលផ្អែកលើទីផ្សារនានា ដើម្បីលើកកម្ពស់ការវិនិយោគលើអាកាសធាតុដែលមានលក្ខណៈឆ្លាតវៃ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមទៅតាមបទបញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថានក្នុងគន្ថីទី១ មាតិកាទី២ និងមាតិកាទី៣ នៃក្រមនេះ ។ | **មាត្រា១៩៣ .**_ ការលើកកម្ពស់ការវិនិយោគលើអាកាសធាតុដែលមានលក្ខណៈឆ្លាតវៃ<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដោយសហការជាមួយនឹងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដោយមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវធ្វើការពិគ្រោះយោបល់ជាមួយនឹងអ្នកពាក់ព័ន្ធទាំងអស់ អំពីវិធានការសារពើពន្ធជាសក្តានុពល បទប្បញ្ញត្តិ ស្តង់ដារនិងយន្តការដែលផ្អែកលើទីផ្សារនានា ដើម្បីលើកកម្ពស់ការវិនិយោគលើអាកាសធាតុដែលមានលក្ខណៈឆ្លាតវៃ ពីវិស័យឯកជនទាំងក្នុង និងក្រៅព្រះរាជាណាចក្រកម្ពុជា ដោយអនុលោមទៅតាមបទបញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ និងសិទ្ធិទទួលបានព័ត៌មានបរិស្ថានក្នុងគន្ថីទី១ មាតិកាទី២ និងមាតិកាទី៣ នៃក្រមនេះ ។<br>មាត្រាថ្មី. បង្កើតបរិយាសកាសអំណោយផលដែលលើកទឹកចិត្ត គាំទ្រ និងការអនុគ្រោះដល់វិ | ប្តូរទៅ១៧៣ និង២០៨<br>ក្រុមស្នើសុំអោយមានមាត្រាច្រើនជាងនេះស្តីពីការលើកទឹកចិត្តដល់វិស័យឯជនដែលវិនិយោគលើអាកាសធាតុដែលមានលក្ខណវៃយឆ្លាត ដូចជា បង្កើតបរិយាកាសអំណោយផល លើកទឹកចិត្ត គាំទ្រ និងអនុគ្រោះដល់វិស័យឯកជនសង្គមស៊ីវិល ឬសហគមន៍ ដែលវិនិយោគអាកាសធាតុ ដែលមានលក្ខណៈវៃឆ្លាត |

| | | | |
|---|---|---|---|
| | | ស័យឯកជនក្នុងការវិនិយោគអាកាសធាតុវៃឆ្លាត | |
| | **មាត្រា១៩៥** ._ ការអង្កេតតាមដានហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុពីបរទេស<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវសហប្រតិបត្តិការជាមួយនឹងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីធ្វើការអង្កេតតាមដានហិរញ្ញវត្ថុ ប្រែប្រួលអាកាសធាតុពីបរទេស និងត្រូវធានាឲ្យមានការដាក់បញ្ចូលនូវការប្រែប្រួលអាកាសធាតុទៅក្នុងកិច្ចចរចានានាជាមួយនឹងដៃគូអភិវឌ្ឍ ស្តីពីយុទ្ធសាស្ត្រសម្រាប់ព្រះរាជាណាចក្រកម្ពុជារបស់ខ្លួន ។ | **មាត្រា១៩៥** ._ ការអង្កេតតាមដានហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុពីបរទេស<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវសហប្រតិបត្តិការជាមួយនឹងក្រសួង ស្ថាប័នទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីធ្វើការអង្កេតតាមដានហិរញ្ញវត្ថុ ការប្រែប្រួលអាកាសធាតុពីបរទេស និងត្រូវធានាឲ្យមានការដាក់បញ្ចូលនូវយុទ្ធសាស្ត្រនៃការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុទៅក្នុងកិច្ចចរចានានាជាមួយនឹងដៃគូអភិវឌ្ឍន៍។ | ប្តូរទៅ២០៩ និង២១០<br>ហិរញ្ញវត្ថុ ឬហិរញ្ញប្បទាន???<br>ការកៀងគរថវិការ គួរតែបញ្ជាក់អោយបានច្បាស់ |
| | **មាត្រា១៩៦** ._ អាជ្ញាធរជាតិដែលត្រូវបានចាត់តាំង<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវតែជាអាជ្ញាធរជាតិដែលត្រូវបានចាត់តាំង សម្រាប់ ការងារហិរញ្ញវត្ថុអាកាស | **មាត្រា១៩៦** ._ អាជ្ញាធរជាតិដែលត្រូវបានចាត់តាំង<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវតែជាអាជ្ញាធរជាតិដែលត្រូវបានចាត់តាំង សម្រាប់ ការងារហិរញ្ញប្បទានអាកាសធាតុ | សូមពិនិត្យមតិយោបល់លើពង្រាងទី៩.១ |

| | | | |
|---|---|---|---|
| | ធាតុដែលផ្អែកលើលទ្ធផល ។ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវ ពិនិត្យមើល ធ្វើការឯកភាព និងផ្ដល់សុពលភាពដល់គម្រោងទាំងអស់ ដែលស្នើសុំការយល់ព្រមពី រាជរដ្ឋាភិបាលកម្ពុជា ដើម្បីចូលរួមនៅក្នុងយន្តការហិរញ្ញប្បទានអាកាសធាតុដែលផ្អែកលើលទ្ធផល រួមមាន យន្តការទាំងឡាយយោងតាមយន្តការអភិវឌ្ឍស្អាត យន្តការនៃការផ្ដល់ឥណទានរួម វិធានការកាត់បន្ថយថ្នាក់ជាតិដ៏សមស្របមួយ ព្រមទាំងយន្តការរេដបូក ជាអាទិ៍ ។ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវធានាថា គម្រោងទាំងនេះ អនុលោមតាមផែនការ និងយុទ្ធសាស្ត្រជាតិ ស្ដីពីការប្រែប្រួលអាកាសធាតុដែលពាក់ព័ន្ធនានា ។ | ដែលផ្អែកលើលទ្ធផល ។ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវ ពិនិត្យមើល ធ្វើការឯកភាព និងផ្ដល់សុពលភាពដល់គម្រោងទាំងអស់ ដែលស្នើសុំការយល់ព្រមពី រាជរដ្ឋាភិបាលកម្ពុជា ដើម្បីចូលរួមនៅក្នុងយន្តការហិរញ្ញប្បទានអាកាសធាតុដែលផ្អែកលើលទ្ធផល រួមមាន យន្តការទាំងឡាយយោងតាមយន្តការអភិវឌ្ឍស្អាត យន្តការនៃការផ្ដល់ឥណទានរួម វិធានការកាត់បន្ថយថ្នាក់ជាតិដ៏សមស្របមួយ ឧទាហរណ៍ យន្តការរេដបូក ជាអាទិ៍ ។ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវធានាថា គម្រោងទាំងនេះ អនុលោមតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រជាតិស្ដីពីការប្រែប្រួលអាកាសធាតុដែលពាក់ព័ន្ធនានា ។ | |
| | **មាត្រា១៩៧ .**_ ការលើកកម្ពស់ការចូលរួមនៅក្នុងយន្តការហិរញ្ញវត្ថុដែលផ្អែកលើលទ្ធផល<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវលើកកម្ពស់ការចូលរួមនៅក្នុងយន្តការហិរញ្ញវត្ថុ អាកាសធាតុដែលផ្អែកលើ | **មាត្រា១៩៧ .**_ ការលើកកម្ពស់ការចូលរួមនៅក្នុងយន្តការហិរញ្ញវត្ថុដែលផ្អែកលើលទ្ធផល<br>ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ត្រូវលើកកម្ពស់ការចូលរួមនៅក្នុងយន្តការហិរញ្ញប្បទាន អាកាសធាតុដែលផ្អែកលើលទ្ធផល មានជាអាទិ៍តាមរយៈ ៖ | សូមពិនិត្យមតិយោបល់លើពង្រាងទី៩.១ |

| | | | |
|---|---|---|---|
| | លទ្ធផល មានជាអាទិ៍តាមរយៈ ៖<br>ក- ការចេញការណែនាំ ស្តីពីការទទួលបានហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុតាមរយៈ ការចូលរួមនៅក្នុងយន្តការហិរញ្ញវត្ថុអាកាសធាតុដែលផ្អែកលើលទ្ធផល ។<br>ខ- ការរក្សា និងការផ្សព្វផ្សាយព័ត៌មានស្តីពីប្រភព ជម្រើសអាទិភាពផ្សេងៗ និងសក្តានុពលសម្រាប់ការកាត់បន្ថយការបំភាយឧស្ម័ននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។<br>គ- ការរក្សា និងការផ្សព្វផ្សាយព័ត៌មានស្តីពីការកាត់បន្ថយការបំភាយឧស្ម័នពី គម្រោងដែលចូលរួមនានាតាមរយៈបញ្ជីថ្នាក់ជាតិសម្រាប់គម្រោងកាត់បន្ថយការបំភាយ ឧស្ម័នផ្ទះកញ្ចក់ រួមមានព័ត៌មានអំពីទំហំនៃការផ្តល់ហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ ដែលបានកៀងគរតាមរយៈ ការចូលរួមរបស់អង្គភាពរដ្ឋ និងអង្គ | ក- ការចេញការណែនាំ ស្តីពីការទទួលបានហិរញ្ញប្បទានអាកាសធាតុតាមរយៈ ការចូលរួមនៅក្នុងយន្តការហិរញ្ញវត្ថុអាកាសធាតុដែលផ្អែកលើលទ្ធផល ។<br>ខ- ការរក្សា និងការផ្សព្វផ្សាយព័ត៌មានស្តីពីប្រភព ជម្រើសអាទិភាពហិរញ្ញប្បទានផ្សេងៗ និង សក្តានុពលសម្រាប់ការកាត់បន្ថយការបំភាយឧស្ម័ននៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមមានព័ត៌មានអំពីទំហំនៃការផ្តល់ហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ ដែលបានកៀងគរតាមរយៈការចូលរួមរបស់អង្គភាពរដ្ឋ អង្គភាពឯកជន និងដៃគូអភិវឌ្ឍន៍នានា នៅក្នុងយន្តការហិរញ្ញប្បទានអាកាសធាតុដែលផ្អែកលើលទ្ធផល និងលទ្ធផលផ្សេងៗដែលសម្រេចបានជាអាទិ៍ ។ | |

<table>
<tr><td></td><td>ភាពឯកជន នៅក្នុងយន្តការហិរញ្ញវត្ថុ អាកាសធាតុដែលផ្អែកលើលទ្ធផល និងលទ្ធផលផ្សេងៗដែលសម្រេចបានជាអាទិ៍ ។</td><td></td><td></td></tr>
<tr><td></td><td colspan="3">មតិយោបល់ថ្មី ក្នុងពង្រាងទី១០<br><br>មាតិកាទី២ ការបម្រែបម្រួលអាកាសធាតុ  នៃពង្រាងទី១០<br><br>ជំពូក២ គួរបន្ថែម មាត្រា ១៧៨ ….. ដោយផ្អែកលើរបាយការណ៍អំពីផលប៉ះពាល់ និង ដំណោះស្រាយពីគ្រប់ប្រភព ។<br>គួរបន្ថែម មាត្រា ១៧៩ ……ដៃគូអភិវឌ្ឍន៍ ( អង្គការសង្គមស៊ីវិលនិង សហាគមន៍មូលដ្ឋាន)<br><br>ជំពូក៣ គួរបន្ថែម មាត្រា ១៨០ ចំណុចខទី៥ ទប់ស្កាត់បទល្មើសព្រៃឈើនៅសហាគមន៍អោយមានប្រសិទ្ធភាពបំផុត<br>មាត្រា១៨១ បន្ថែម ចំណុចទី២ បន្ថែមសង្គមស៊ីវិល និង សហាគមន៍មូលដ្ឋាន<br>មាត្រា ១៨៣ លិខិតបទដ្ឋាន ធ្វើបច្ចុប្បន្នភាព ពី២ទៅ៣ឆ្នាំ<br><br>ជំពូក៤ និង ជំពូក ៥ អានទៅហាក់ដូចជាមានលិខិតបទដ្ឋានគតិយុត្តច្រើន បារម្ភជាន់គ្នា គួរពិនិត្យឡើងវិញ<br>មាត្រា ២០២ សុំមានយន្តការធានាការទូទាត់ថ្លៃលក់កាបូន ដោយសមធម៌ និងសមរម្យបំផុត ព្រមទាំងបញ្ជាក់ពីចំនួនភាគរយនៃការបែងចែកផលប្រយោជន៍នៃការលក់កាបូនសំរាប់សហាគមន៍មូលដ្ឋាន<br>ជំពូក៥<br>- ផ្នែកទី២ មាត្រា ២០៨ គួរបញ្ចូលអង្គការសង្គមស៊ីវិល និង សហាគមន៍មូលដ្ឋាន<br>- ផ្នែកទី៣ មាត្រា ២០៩ គួរមានការធ្វើសវនកម្មលើហិរញ្ញប្បទានទាក់ទងនឹងការលក់កាបូន ការវិយោគ និង ជំនួយបរទេសលើកាបំរែបំរួលអាកាសធាតុ</td></tr>
</table>

| | |
|---|---|
| | - មាត្រា ២១០ គួរមានក្រុមសវនកម្មឯករាជ្យ អាចក្នុងស្រុក និង ក្រៅស្រុក<br>- មាត្រា ២០១១និង ២០១២ មានយន្តការទូទាត់លក់កាប៉ូនក្នុងការសម្រេចចិត្តពីសហគមន៍ |
| | **មតិយោបល់ថ្មីក្នុងគន្ធីទី៣ មាតិកាទី១ ការកាត់បន្ថយ និង ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ នៃពង្រាងទី១០**<br><br>**មាត្រា១៦៧ ._ វិសាលភាព**<br>**សូមបន្ថែម៖**<br>មាតិកានេះមានវិសាលភាពអនុវត្តចំពោះសកម្មភាព ការគ្រប់គ្រង និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។<br>…..យន្តការនៃការដឹកនាំការគ្រប់គ្រង …….<br><br>**មាត្រាទី១៦៨**<br>ស្នើសុំកែប្រែពាក្យពី (គ្រប់គ្រងគ្រោះមហន្តរាយ)ទៅជា គ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ (from “disaster management” to “disaster risk management” ) ដោយនៅក្នុងពាក្យនេះ មានរួមបញ្ចូលនៅការត្រៀមបង្ការ ដើម្បីកាត់បន្ថយគ្រោះភ័យ និង គ្រោះមហន្តរាយ។<br>សូមបញ្ចូលការបញ្ជ្រាប ការគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ ជាមួយនិង ការប្រែប្រួលអាកាសធាតុ ទៅក្នុងការរៀបចំផែនការរយៈពេលវែង<br>**ស្នើសុំបញ្ចូល៖** អង្គការសង្គមស៊ីវិល ក្នុងការរៀបចំផែនការ និង ពិគ្រោះយោបល់ (បើអត់មានបញ្ជាក់អំពីការចូលរួមរបស់សង្គមស៊ីវិលដូចជាមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយពីដៃគូរពាក់ព័ន្ធ)។<br>សូមបន្ថែម សហគមន៍មូលដ្ឋានផងដែរ …… ពីព្រោះពួគគេជាអ្នករងគ្រោះ និង មានបទពិសោធន៍ក្នុងគ្រោះមហន្តរាយ។<br><br>**មាត្រាទី១៦៩ ៖** ការរៀបចំផែនការគ្រប់គ្រងគ្រោះមហន្តរាយ ដែលប៉ះពាល់ដល់បរិស្ថាន |

ត្រូវ ផ្អែកតាមរយៈច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ (អនុម័តិ ខែ កក្កដា ឆ្នាំ ២០១៥) ត្រូវលើកយកបញ្ជាក់ ដើម្បីអនុវត្ត ពង្រឹងការចូលរួមទទួលខុសត្រូវ នៅតាមសាមីក្រសួងក្នុងការរៀបចំ ចាត់តាំងអោយមានលេខាធិការដ្ឋានទទួលខុសត្រូវលើការងារ គ្រប់គ្រងគ្រោះមហន្តរាយ អោយមានប្រសិទ្ធភាពខ្ពស់ ផ្សារភ្ជាប់ជាមួយនៅថវិកាសម្រាប់អនុវត្ត៕

សូមបន្ថែម

ការវាយតម្លៃ គួរតែមានគណៈកម្មការវាយតម្លៃដោយឯករាជ្យ ជាក្រុមការងារចម្រុះ( ស្ថាប័នជាតិ ថ្នាក់ជាតិ និងក្រោមជាតិ វិស័យឯកជន អង្គការសង្គមស៊ីវិល និង សហាគមន៍មូលដ្ឋាន

**មាត្រា ១៧២៖** ការពិគ្រោះយោបល់ស្តីពីការគ្រប់គ្រង និងកាត់បន្ថយហានិភ័យ

**គួរបន្ថែម** កិច្ចសហការថ្នាក់តំបន់ និង អន្តរជាតិ ជាពិសេសគឺ ការឆ្លើយតបបន្ទាន់ ឬ ការព្យាករណ៍ជាមុនពីហានិភ័យគ្រោះមហន្តរាយ

**គួរបន្ថែម** ការរៀបចំកញ្ចប់ថវិកាសម្រាប់ការសង្គ្រោះបន្ទាន់ ឬ ការឆ្លើយតបនឹងផ្នែកមនុស្សធម៌ ជាជាងការរំពឹងតែពីជំនួយរបស់កាកបាទក្រហម និង ជំនួយខាងក្រៅផ្សេងៗទៀត ដែលអាចធ្វើឱ្យសកម្មភាពឆ្លើយតបមានការយឺតយ៉ាវ។

**មាត្រាទី១៦៨ និង១៧២**

**ស្នើសុំបញ្ចូល** អង្គការសង្គមសីវិល ក្នុងការរៀបចំផែនការ និង ពិគ្រោះយោបល់ (បើអត់មានបញ្ជាក់អំពីការចូលរួមរបស់សង្គមសីវិលដូចជាមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយពីដៃគូរពាក់ព័ន្ធ)។ បន្ថែម សហគមន៍មូលដ្ឋានផងដែរ ...... ពីព្រោះពួគគេជាអ្នករងគ្រោះ និង មានបទពិសោធន៍ក្នុងគ្រោះមហន្តរាយ

គួរបន្ថែម កិច្ចសហការថ្នាក់តំបន់ និង អន្តរជាតិ ជាពិសេសគឺ ការឆ្លើយតបបន្ទាន់ ឬ ការព្យាករណ៍ជាមុនពីហានិភ័យគ្រោះមហន្តរាយ

គួរបន្ថែម ការរៀបចំកញ្ចប់ថវិកាសម្រាប់ការសង្គ្រោះបន្ទាន់ ឬ ការឆ្លើយតបនឹងផ្នែកមនុស្សធម៌ ជាជាងការរំពឹងតែពីជំនួយរបស់កាកបាទក្រហម និង ជំនួយខាងក្រៅផ្សេងៗទៀត ដែលអាចធ្វើឱ្យសកម្មភាពឆ្លើយតបមានការយឺតយ៉ាវ។

**មាត្រា១៧៨** ._ ការរៀបចំផែនការវិនិយោគ និងការអភិវឌ្ឍ

**ជំពូក២** គួរបន្ថែម មាត្រា ១៧៨ ….. ដោយផ្អែកលើរបាយការណ៍អំពីផលប៉ះពាល់ និង ដំណោះស្រាយពីគ្រប់ប្រភព ។

**មាត្រា១៧៩** ._ ផែនការ និងយុទ្ធសាស្ត្រឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ

គួរបន្ថែម មាត្រា ១៧៩ ……ដៃគូអភិវឌ្ឍន៍ ( អង្គការសង្គមស៊ីវិលនិង សហាគមន៍មូលដ្ឋាន)

**មាត្រា១៨០** ._ ការអនុវត្តការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ

**ជំពូក៣** គួរបន្ថែម មាត្រា ១៨០ ចំណុចខទី៥ ទប់ស្កាត់បទល្មើសព្រៃឈើនៅសហាគមន៍អោយមានប្រសិទ្ធភាពបំផុត

**មាត្រា១៨១** ._ កិច្ចសហការ និងភាពជាដៃគូក្រសួង ស្ថាប័នទទួលបន្ទុកអភិវឌ្ឍន៍ដោយចីរភាព ត្រូវះ

មាត្រា១៨១ បន្ថែម ចំណុចទី២ បន្ថែមសង្គមស៊ីវិល និង សហាគមន៍មូលដ្ឋាន

**មាត្រា១៨៣** ._ លិខិតបទដ្ឋានគតិយុត្តសម្រាប់ការបន្សាំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ

មាត្រា ១៨៣ លិខិតបទដ្ឋាន ធ្វើបច្ចុប្បន្នភាព ពី២ទៅ៣ឆ្នាំ

**មាត្រា២០២** ._ ការអនុវត្តតាមបញ្ជីថ្នាក់ជាតិសម្រាប់គម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់

ជំពូក៤ និង ជំពូក ៥ អានទៅហាក់ដូចជាមានលិខិតបទដ្ឋានគតិយុត្តច្រើន បារម្ភជាន់គ្នា គួរពិនិត្យឡើងវិញ

មាត្រា ២០២ សុំមានយន្តការធានាការទូទាត់ថ្លៃលក់កាបូន ដោយសមធម៌ និងសមរម្យបំផុត ព្រមទាំងបញ្ជាក់ពីចំនួនភាគរយនៃការបែងចែកផលប្រយោជន៍នៃការលក់កាបូនសំរាប់សហាគមន៍មូលដ្ឋាន

**មាត្រា២០៨** ._ ការលើកកម្ពស់ការវិនិយោគដែលគិតគូរចំពោះការប្រែប្រួលអាកាសធាតុ

| | |
|---|---|
| | ជំពូក៥<br> ផ្នែកទី២ មាត្រា ២០៨ គួរបញ្ចូលអង្គការសង្គមស៊ីវិល និង សហគមន៍មូលដ្ឋាន<br><br>**មាត្រា២០៩**._ ការសម្របសម្រួលអំពីហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុពីបរទេស<br>ផ្នែកទី៣ មាត្រា ២០៩ គួរមានការធ្វើសវនកម្មលើហិរញ្ញប្បទានទាក់ទងនឹងការលក់កាបូន ការវិយោគ និង ជំនួយបរទេសលើកាបំរែបំរួលអាកាសធាតុ<br><br>**មាត្រា២១០**._ ការត្រួតពិនិត្យហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុពីបរទេស<br>មាត្រា ២១០ គួរមានក្រុមសវនកម្មឯករាជ្យ អាចក្នុងស្រុក និង ក្រៅស្រុក<br><br>**មាត្រា២១១**._ យន្តការទូទាត់ថ្លៃលក់កាបូន<br>មាត្រា ២០១១និង ២០១២ មានយន្តការទូទាត់លក់កាបូនក្នុងការសម្រេចចិត្តពីសហគមន៍<br><br>**មាត្រា២១៥**.ការប្រើប្រាស់ដោយចីរភាព<br>បន្ថែម<br>ចំនុចទី៦ ឧស្ម័នបំពុល/ ផ្ទះកញ្ចក់<br>ចំនុចទី៧ សារធាតុគីមីកសិកម្ម លើដី និងក្នុងទឹក<br>ពន្យល់បន្ថែម<br><br>៣- កូតាសម្រាប់ការយកផលិតផលត្រឡប់មកវិញ ។ |

| | |
|---|---|
| | **មាត្រា២៣២ ._** តួនាទី និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន<br>ប្តូរពាក្យ «អ្នកពាក់ព័ន្ធមិនមែនរដ្ឋាភិបាល» ទៅ «សង្គមស៊ីវិល និងប្រជាពលរដ្ឋអ្នកពាក់ព័ន្ធ»<br><br>៩- ការបង្កើតឱ្យមានការចូលរួមរវាងក្រសួង ស្ថាប័នមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធមិនមែនរដ្ឋាភិបាល ដើម្បីធ្វើការផ្លាស់ប្តូរចំណេះដឹង ព័ត៌មាន និងកង្វល់ពាក់ព័ន្ធទៅនឹងផែនការប្រើប្រាស់ដីធ្លី និងការរៀបចំទីក្រុងដោយចីរភាព ។<br><br>**មាត្រា២៣៧ ._** សិទ្ធិទទួលបានព័ត៌មានអំពីផែនការប្រើប្រាស់ដីដែលយកចិត្តទុកដាក់ដល់បរិស្ថាន<br>សូមបញ្ជាក់អោយបានលំអិតពី ព័ត៌មានត្រូវដាក់អោយប្រជាជនអាចស្វែងរកបាន ដោយរៀបណាឬ វីធីណា?<br><br>**មាត្រា២២០ ._** ការរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីស្លាកសញ្ញាបរិស្ថាន<br>គួរមានស្ថាប័នឯករាជ្យក្នុងការចេញវិញ្ញាបនបត្របញ្ជាក់ និងការធ្វើសវនកម្ម។ |

# មតិយោបល់របស់អង្គការសង្គមស៊ីវិល

# លើសេចក្តីព្រាងទី១០នៃ ក្រមបរិស្ថាន និង ធនធានធម្មជាតិ នៃព្រះរាជាណាចក្រកម្ពុជា

# ប្រធានបទ៖ ការគ្រប់គ្រងរួមគ្នា

| លរ NO | គន្លឹ/មាតិកា/ជំពូកក្នុងពង្រាងទី៩<br>**Book/Title**<br>**(Copy and Paste from Environment Code)** | មតិយោបល់របស់សង្គមស៊ីវិល លើពង្រាងទី ៩.១ | សំណូមពរ/កំណែប្រែថ្មី លើពង្រាងទី ១០<br>( CSO Suggestions ) |
|---|---|---|---|
| | **មាត្រា៣១២** ._ បទពិសោធន៍ និងការបណ្តុះបណ្តាលដែលចាំបាច់<br>នាយករបៀងអភិរក្សជីវៈចម្រុះ នាយកតំបន់ការពារធម្មជាតិ របៀងអភិរក្សជីវៈចម្រុះតាមវិស័យដទៃទៀត និងបុគ្គលិកផ្នែកបច្ចេកទេស និងផ្នែកគ្រប់គ្រងនៃតំបន់ការពារដែលត្រូវបានកំណត់ដោយថ្នាក់ជាតិ ប្រធានមន្ទីរបរិស្ថានខេត្ត ត្រូវបានតែងតាំង ដោយផ្អែកលើអ្នកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចខាងក្រោម៖<br>១- ផ្នែកអប់រំ និងជំនាញវិជ្ជាជីវៈដែលចាំបាច់ ។<br>២- បទពិសោធន៍ក្នុងវិស័យព្រៃឈើ ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ការអភិរក្សជីវៈ | **មាត្រា៣១២** ._ បទពិសោធន៍ និងការបណ្តុះបណ្តាលដែលចាំបាច់<br>នាយករបៀងអភិរក្សជីវៈចម្រុះ នាយកតំបន់ការពារធម្មជាតិ របៀងអភិរក្សជីវៈចម្រុះតាមវិស័យដទៃទៀត និងបុគ្គលិកផ្នែកបច្ចេកទេស និងផ្នែកគ្រប់គ្រងនៃតំបន់ការពារដែលត្រូវបានកំណត់ដោយថ្នាក់ជាតិ ប្រធានមន្ទីរបរិស្ថានខេត្ត ត្រូវបានតែងតាំង ដោយផ្អែកលើអ្នកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចខាងក្រោម៖<br>១- ផ្នែកអប់រំ និងជំនាញវិជ្ជាជីវៈដែលចាំបាច់ ។<br>២- បទពិសោធន៍ក្នុងវិស័យព្រៃឈើ ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការ | មានត្រានេះត្រូវបានកាត់ចោល នៅក្នុងសេចក្តីពង្រាង ១០ ។ ក្រុមមិនមានការកង្វល់ លើចំនុចនេះទេ ពីវានិយាយតែពីសមាសភាពនៃអ្នកគ្រប់គ្រង។ |

| | | | |
|---|---|---|---|
| | ចម្រុះ ការពង្រឹងការអនុវត្តច្បាប់ និងវិស័យពាក់ព័ន្ធដទៃៗទៀត ។<br>នាយករបៀងអភិរក្សជីវៈចម្រុះ នាយកតំបន់ការពារធម្មជាតិ និងបុគ្គលិកផ្នែករបៀងអភិរក្សចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ដោយថ្នាក់ជាតិ និងប្រធានមន្ទីរទទួលបន្ទុកវិស័យបរិស្ថានខេត្តដែលពាក់ព័ន្ធ ត្រូវបំពេញវគ្គសិក្សា និងវគ្គបណ្តុះបណ្តាល នៅបណ្ឌិតសភាបណ្តុះបណ្តាលផ្នែកបរិស្ថានជាតិ និងធនធានធម្មជាតិក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។ | ពង្រឹងការអនុវត្តច្បាប់ បញ្ហាសង្គម និងវិស័យពាក់ព័ន្ធដទៃៗទៀត ។<br>នាយករបៀងអភិរក្សជីវៈចម្រុះ នាយកតំបន់ការពារធម្មជាតិ និងបុគ្គលិកផ្នែករបៀងអភិរក្សចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ដោយថ្នាក់ជាតិ និងប្រធានមន្ទីរទទួលបន្ទុកវិស័យបរិស្ថានខេត្តដែលពាក់ព័ន្ធ ត្រូវបំពេញវគ្គសិក្សា និងវគ្គបណ្តុះបណ្តាល នៅបណ្ឌិតសភាបណ្តុះបណ្តាលផ្នែកបរិស្ថានជាតិ និងធនធានធម្មជាតិក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន ។ | |
| | **មាត្រា៣២៩** ._ ការអភិវឌ្ឍដែលត្រូវបានអនុញ្ញាតនៅក្នុងតំបន់គ្រប់គ្រង<br>ការអភិវឌ្ឍអគារ ឬហេដ្ឋារចនាសម្ព័ន្ធអចិន្ត្រៃយ៍ សកម្មភាពពាណិជ្ជកម្មគ្រប់ប្រភេទ ការឈូសឆាយដី ឬការឈូសឆាយដោយប្រើគ្រឿងចក្រ ត្រូវហាមឃាត់យ៉ាងតឹងរ៉ឹងនៅក្នុងតំបន់ស្នូល និងតំបន់អភិរក្ស ។<br>ហេដ្ឋារចនាសម្ព័ន្ធដែលមិនមានលក្ខណ:អចិន្ត្រៃយ៍ ដែលមានផលប៉ះពាល់ | **មាត្រា៣២៩** ._ ការអភិវឌ្ឍដែលត្រូវបានអនុញ្ញាតនៅក្នុងតំបន់គ្រប់គ្រង<br>ការអភិវឌ្ឍអគារ ឬហេដ្ឋារចនាសម្ព័ន្ធអចិន្ត្រៃយ៍ សកម្មភាពពាណិជ្ជកម្មគ្រប់ប្រភេទ ការឈូសឆាយដី ឬការឈូសឆាយដោយប្រើគ្រឿងចក្រ ត្រូវហាមឃាត់យ៉ាងតឹងរ៉ឹងនៅក្នុងតំបន់ស្នូល និងតំបន់អភិរក្ស ។<br>ហេដ្ឋារចនាសម្ព័ន្ធដែលមិនមានលក្ខណ:អចិន្ត្រៃយ៍ ដែលមានផលប៉ះពាល់ទាបដែលស៊ីចង្វាក់គ្នាជាមួយនឹងផែនការគ្រប់គ្រង | មាត្រានេះលែងមាននៅក្នុងសេចក្តីព្រាង ១០ ហើយ |

| | | | |
|---|---|---|---|
| | ទាប ដែលស៊ីចង្វាក់គ្នាជាមួយនឹងផែនការគ្រប់គ្រងតំបន់ អាចត្រូវបានអនុញ្ញាតនៅក្នុងតំបន់ស្នូលនិងតំបន់ អភិរក្ស ។<br>សកម្មភាពពាណិជ្ជកម្ម នៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព ឬតំបន់សហគមន៍ ត្រូវតែមានភាពស៊ីចង្វាក់គ្នាជាមួយផែនការគ្រប់គ្រងសម្រាប់តំបន់ទាំងនេះ ។ ការឆ្ការ/ឈូសឆាយព្រៃឈើ និងសកម្មភាពអាជីវកម្មព្រៃឈើទ្រង់ទ្រាយធំ មិនត្រូវអនុញ្ញាតឡើយនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ ប៉ុន្តែសកម្មភាពពាណិជ្ជកម្មអាចត្រូវបានអនុញ្ញាតនៅក្នុងអនុតំបន់គ្រប់គ្រង ដែលត្រូវបានបង្កើតឡើងជាពិសេស ស្របតាមមាត្រា៣២២ នៃក្រមនេះ ។ ប្រាក់ចំណូលដែលបានមកពីសកម្មភាពពាណិជ្ជកម្មបែបនេះ ត្រូវប្រើប្រាស់សម្រាប់ជាផលប្រយោជន៍ដោយផ្ទាល់នៃសហគមន៍មូលដ្ឋាននៅក្នុងតំបន់នោះ និងសម្រាប់ការអភិរក្សតំបន់ដែលសកម្មភាពពាណិជ្ជកម្មនោះស្ថិតនៅ ។ | តំបន់ អាចត្រូវបានអនុញ្ញាតនៅក្នុង តំបន់អភិរក្ស ។<br>សកម្មភាពពាណិជ្ជកម្ម នៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព ឬតំបន់សហគមន៍ ត្រូវតែមានភាពស៊ីចង្វាក់គ្នាជាមួយផែនការគ្រប់គ្រងសម្រាប់តំបន់ទាំងនេះ ។ ការឆ្ការ/ឈូសឆាយព្រៃឈើ និងសកម្មភាពអាជីវកម្មព្រៃឈើទ្រង់ទ្រាយធំ មិនត្រូវអនុញ្ញាតឡើយនៅក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ ប៉ុន្តែសកម្មភាពពាណិជ្ជកម្មអាចត្រូវបានអនុញ្ញាតនៅក្នុងអនុតំបន់គ្រប់គ្រង ដែលត្រូវបានបង្កើតឡើងជាពិសេស ស្របតាមមាត្រា៣២២ នៃក្រមនេះ ។ ប្រាក់ចំណូលដែលបានមកពីសកម្មភាពពាណិជ្ជកម្មបែបនេះ ត្រូវប្រើប្រាស់សម្រាប់ជាផលប្រយោជន៍ដោយផ្ទាល់នៃសហគមន៍មូលដ្ឋាននៅក្នុងតំបន់នោះ និងសម្រាប់ការអភិរក្សតំបន់ដែលសកម្មភាពពាណិជ្ជកម្មនោះស្ថិតនៅ ។<br>សកម្មភាពពាណិជ្ជកម្មទាំងនេះក៏ត្រូវអនុលោមតាមបទប្បញ្ញត្តិស្តីពីការចូលរួមជាសាធារណៈ នៅក្នុងគន្ថីទី១ មាតិកាទី២ និងបទប្បញ្ញត្តិស្តីពីសិទ្ធិទទួលបានព័ត៌មានដូចមានចែងក្នុងគន្ថីទី១ | |

| | | | |
|---|---|---|---|
| | សកម្មភាពពាណិជ្ជកម្មទាំងនេះក៏ត្រូវអនុលោមតាមបទប្បញ្ញត្តិស្ដីពីការចូលរួមជាសាធារណៈនៅក្នុងគន្ថីទី១ មាតិកាទី២ និងបទប្បញ្ញត្តិស្ដីពីសិទ្ធិទទួលបានព័ត៌មានដូចមានចែងក្នុងគន្ថីទី១ មាតិកាទី៣ នៃក្រមនេះ និងត្រូវមានការឯកភាពពីក្រសួង ស្ថាប័នពាក់ព័ន្ធ ឬអង្គភាពដែលមានសមត្ថកិច្ចគ្រប់នៅក្នុងតំបន់ ។ | មាតិកាទី៣ នៃក្រមនេះ និងត្រូវមានការឯកភាពពីក្រសួង ស្ថាប័នពាក់ព័ន្ធ ឬអង្គភាពដែលមានសមត្ថកិច្ចគ្រប់នៅក្នុងតំបន់ ។ | |
| | **មាត្រា៣៣៧** ._ ទេសចរណ៍ធម្មជាតិលក្ខណៈពាណិជ្ជកម្ម<br>រូបវន្តបុគ្គល នីតិបុគ្គល ឬសហគមន៍ដែលអនុវត្តទេសចរណ៍ធម្មជាតិលក្ខណៈពាណិជ្ជកម្ម នៅក្នុងព្រៃនៃរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវមានកិច្ចព្រមព្រៀងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ឬគណៈកម្មការគ្រប់គ្រងរួមគ្នា សម្រាប់សកម្មភាព និងការរៀបចំទេសចរណ៍ធម្មជាតិដែលបានស្នើសុំ ។ | **មាត្រា៣៣៧** ._ ទេសចរណ៍ធម្មជាតិលក្ខណៈពាណិជ្ជកម្ម<br>រូបវន្តបុគ្គល នីតិបុគ្គល ឬសហគមន៍ដែលអនុវត្តទេសចរណ៍ធម្មជាតិលក្ខណៈពាណិជ្ជកម្ម នៅក្នុងព្រៃនៃរបៀងអភិរក្សជីវៈចម្រុះ តំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវមានកិច្ចព្រមព្រៀងជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ឬគណៈកម្មការគ្រប់គ្រងរួមគ្នា សម្រាប់សកម្មភាព និងការរៀបចំទេសចរណ៍ធម្មជាតិដែលបានស្នើសុំ ដែលភ្ជាប់មកជាមួយនូវផែនការអភិវឌ្ឍទេសចរណ៍។ | មាត្រានេះលែង នៅក្នុងពង្រាង ១០ ហើយ |

| | | | |
|---|---|---|---|
| | នៅពេលពិចារណាអំពីសំណើសុំប្រតិបត្តិការទេសចរណ៍ធម្មជាតិបន្ថែម ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាជ្ញាធរថ្នាក់ក្រោមជាតិ គណៈកម្មការគ្រប់គ្រងរួមគ្នា ត្រូវពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ដៃគូបច្ចេកទេសពាក់ព័ន្ធដែលមានបទពិសោធស្រាវជ្រាវ ការពារ និងគ្រប់គ្រងធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងសហគមន៍ទាំងឡាយណាដែលកំពុងធ្វើប្រតិបត្តិការទេសចរណ៍ធម្មជាតិរួចទៅហើយ នៅក្នុងតំបន់ជុំវិញនៃសកម្មភាពស្នើសុំ ។ | នៅពេលពិចារណាអំពីសំណើសុំប្រតិបត្តិការទេសចរណ៍ធម្មជាតិបន្ថែម ក្រសួង ស្ថាប័នទទួលបន្ទុកវិស័យបរិស្ថាន អាជ្ញាធរថ្នាក់ក្រោមជាតិ គណៈកម្មការគ្រប់គ្រងរួមគ្នា ត្រូវពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ ដៃគូបច្ចេកទេសពាក់ព័ន្ធដែលមានបទពិសោធស្រាវជ្រាវ ការពារ និងគ្រប់គ្រងធនធានធម្មជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងសហគមន៍ទាំងឡាយណាដែលកំពុងធ្វើប្រតិបត្តិការទេសចរណ៍ធម្មជាតិរួចទៅហើយ នៅក្នុងតំបន់ជុំវិញនៃសកម្មភាពស្នើសុំ ។ | |
| | **មាត្រា៣៤០** ._ វិសាលភាពនៃការអនុវត្ត<br>មាតិកានេះអនុវត្តចំពោះដំបន់ទាំងឡាយ ដែលអាចទទួលបានការអនុវត្តតាមការគ្រប់គ្រងរួមគ្នា។ គ្រប់របៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សហគមន៍តំបន់ការពារធម្មជាតិ  សមាគមន៍ព្រៃឈើ សហគមន៍នានាដែលបានដាក់ពាក្យស្នើសុំការកំណត់ជាសហគមន៍ព្រៃឈើពីមុនរួចហើយ ឬដែលបាន | **មាត្រា៣៤០** ._ វិសាលភាពនៃការអនុវត្ត<br>មាតិកានេះអនុវត្តចំពោះតំបន់ទាំងឡាយ ដែលអាចទទួលបានការអនុវត្តតាមការគ្រប់គ្រងរួមគ្នា។ គ្រប់របៀងអភិរក្សជីវៈចម្រុះ និងតំបន់ការពារធម្មជាតិដែលត្រូវបានកំណត់ ឬបង្កើតដោយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សហគមន៍តំបន់ការពារធម្មជាតិ  សមាគមន៍ព្រៃឈើ សហគមន៍នានាដែលបានដាក់ពាក្យស្នើសុំការកំណត់ជាសហគមន៍ព្រៃឈើពីមុនរួចហើយ ឬដែលបានត្រៀមឯកសារបំណងនឹង | មាត្រនេះលែងមាននៅក្នុងសេចក្ដីពង្រាង ១០ |

| | | | |
|---|---|---|---|
| | ត្រៀមឯកសារបំណងនឹងដាក់ពាក្យស្នើសុំការកំណត់ជាសហគមន៍ព្រៃឈើ ដីសាធារណៈរបស់រដ្ឋដទៃទៀតដែលមានតម្លៃអភិរក្ស និងតម្លៃប្រព័ន្ធអេកូឡូស៊ី ដីបម្រុងទុករបស់ជនជាតិដើមភាគតិច ឬដីជាលក្ខណៈប្រពៃណីដទៃទៀត ត្រូវមានសិទ្ធិទទួលបានការគ្រប់គ្រងស្របតាមគោលការណ៍នៃការគ្រប់គ្រងរួមគ្នាដូចមានចែងក្នុងមាតិកានេះ។ | ដាក់ពាក្យស្នើសុំការកំណត់ជាសហគមន៍ព្រៃឈើ ដីសាធារណៈរបស់រដ្ឋដទៃទៀតដែលមានតម្លៃអភិរក្ស និងតម្លៃប្រព័ន្ធអេកូឡូស៊ី ដីបម្រុងទុក របស់ជនជាតិដើមភាគតិច ឬដីជាលក្ខណៈប្រពៃណីដទៃទៀត ត្រូវមានសិទ្ធិទទួលបានការគ្រប់គ្រងស្របតាមគោលការណ៍នៃការគ្រប់គ្រងរួមគ្នាដូចមានចែងក្នុងមាតិកានេះ។ | |

**មតិយោបល់ថ្មីក្នុងមាត្រាទី ៣១៣ នៃពង្រាងទី១០**

**មាត្រា៣១៣** ._ សមាសភាគនៃតំបន់ដែលមានសក្តានុពល និងលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបង្កើតជាតំបន់គ្រប់គ្រងរួមគ្នា

សមាសភាគប្រព័ន្ធតំបន់ការពារធម្មជាតិ សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ សហគមន៍ដែលបានដាក់ពាក្យស្នើសុំបង្កើតជាសហគមន៍ព្រៃឈើរួចហើយ ឬសហគមន៍ដែលបានរៀបចំឯកសាគ្រប់គ្រាន់ដើម្បីដាក់ពាក្យសុំបង្កើតជាសហគមន៍ព្រៃឈើ សហគមន៍នេសាទ ដីសាធារណៈរបស់រដ្ឋ ឬធនធានទឹកដែលមានតម្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី ដីដែលបានធ្វើចំណាត់ថ្នាក់សម្រាប់ការគ្រប់គ្រងព្រៃឈើដោយចីរភាព និងដីអភិរក្សជាលក្ខណៈប្រពៃណីរបស់ជនជាតិដើមភាគតិច ត្រូវកំណត់ជាសមាសភាគនៃតំបន់ដែលមានសក្តានុពល និងលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបង្កើតជាតំបន់គ្រប់គ្រងរួមគ្នា។

**មតិយោបល់៖ លែងមាន**

**មាត្រា៣១៥** ._ គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងរួមគ្នា

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងរួមគ្នា ក្នុងរយៈពេល ៣ (បី) ឆ្នាំ ក្រោយពេលក្រមនេះចូលជាធរមាន ។

| |
|---|
| **មតិយោបល់៖**តើក្រោយរយៈពេល ៣ ឆ្នាំ តើស្ថាប័ន នណាខ្លះដែលចូលរួម រៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងរួមគ្នា? វាហាក់ដូចជាអត់ច្បាប់ ។ ចំពោះការរៀបចំ រៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងរួមគ្នា គួរបើកឲ្យមានពិគ្រោះយោបល់ និងការការពិភាក្សាតំណាងសហគមន៍ និង សង្គមស៊ីវិល។<br>តើនៅពេលបីឆ្នាំក្រោយ នណាជាអ្នកឆ្លើយតបទៅហ្នឹងសេចក្តីបានកំណត់នេះ។ |
| **មាត្រា៣១៦** ._ សិទ្ធិដើម្បីធ្វើការគ្រប់គ្រងរួមគ្នា<br>សហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងអង្គការសង្គមស៊ីវិលពាក់ព័ន្ធ ដោយសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ មានសិទ្ធិដើម្បីរៀបចំ និងធ្វើការគ្រប់គ្រងរួមគ្នាលើតំបន់ដែលត្រូវធ្វើការគ្រប់គ្រងរួមគ្នា ។<br><br>**មតិយោបល់៖** មិនចំទាស់ ប៉ុន្តែតើនិវិធីនៃការស្នើសិទ្ធិនៃការគ្រប់គ្រងរួមគ្នានេះ ហ្នឹងត្រូវស្នើសុំទៅអ្នកណា? |
| **មាត្រា៣១៧** ._ ការរៀបចំការគ្រប់គ្រងរួមគ្នា<br>តំណាងសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់លក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ដូចខាងក្រោម ៖<br>១- វចនាសម្ព័ន្ធនៃការគ្រប់គ្រងរួមគ្នា ។<br>២- សមាជិកភាព និងសិទ្ធិបោះឆ្នោតរបស់សមាជិកសហគមន៍គ្រប់គ្រងរួមគ្នា ។<br>៣- សំណើកំណត់តំបន់គ្រប់គ្រង សម្រាប់តំបន់គ្រប់គ្រងរួមគ្នា និងសំណើផែនការគ្រប់គ្រងរួមគ្នា ។ ឯកសារទាំងពីរនេះ ត្រូវរៀបចំទៅតាមស្តង់ដារដែលស្របតាមសមត្ថភាព និងធនធានមូលដ្ឋាន ដែលឆ្លុះបញ្ចាំងពីចំណេះដឹង និងចក្ខុវិស័យនៃអ្នកតំណាងសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលទទួលខុសត្រូវក្នុងការអនុវត្តការគ្រប់គ្រងរួមគ្នា ។<br>លក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ត្រូវស្របតាមផែនការប្រើប្រាស់ដីធ្លីជាធរមាន ដែលទាក់ទងនឹងផ្នែកណាមួយនៃតំបន់ដែលត្រូវគ្រប់គ្រងរួមគ្នា |

ការកំណត់តំបន់គ្រប់គ្រង និងផែនការគ្រប់គ្រងសម្រាប់ការគ្រប់គ្រងរួមគ្នា ត្រូវដាក់បញ្ចូលនូវការកំណត់តំបន់គ្រប់គ្រងដែលមានស្រាប់ ការកំណត់តំបន់គ្រប់គ្រងថ្មី និងផែនការគ្រប់គ្រងដែលត្រូវរៀបចំឡើង ត្រូវស្របតាមបទប្បញ្ញត្តិស្តីពីប្រព័ន្ធតំបន់ការពារធម្មជាតិនៃក្រមនេះ ។

**មតិយោបល់៖**

តើអ្វីជាស្តង់ដារដែលសមស្រប? អ្នកណាជាអ្នកបង្កើតស្តង់នេះ? ពេលណា?
តើផែនការប្រើប្រាស់ដីធ្លីជាធរមាន នេះ ជារបស់ស្ថាប័នណា? នណាជាអ្នកកំណត់?
ក្នុងលក្ខខ័ណដែលតំបន់នោះមិនទាន់មានផែនការប្រើប្រាស់ដីធ្លីជាធរមាន ហ្នឹងមិនអាចមានការរៀបចំការគ្រប់គ្រងរួមគ្នា ឬយ៉ាងណា?
មាត្រានេះពិបាក់យល់ ហើយមានលក្ខណៈប្រឆាំងគ្នាក្នុងក្រមខ្លួនឯង *ការកំណត់តំបន់គ្រប់គ្រង និងផែនការគ្រប់គ្រងសម្រាប់ការគ្រប់គ្រងរួមគ្នា ត្រូវដាក់បញ្ចូលនូវការកំណត់តំបន់គ្រប់គ្រងដែលមានស្រាប់ ការកំណត់តំបន់គ្រប់គ្រងថ្មី និងផែនការគ្រប់គ្រងដែលត្រូវរៀបចំឡើង ត្រូវស្របតាមបទប្បញ្ញត្តិស្តីពីប្រព័ន្ធតំបន់ការពារធម្មជាតិនៃក្រមនេះ ។*

**មាត្រា៣១៨** ._ ការគាំទ្រសម្រាប់ការគ្រប់គ្រងរួមគ្នា

តំណាងសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវសហការជាមួយក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន មន្ត្រីរាជការពាក់ព័ន្ធមកពីសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ និងក្រសួង ស្ថាប័នមានសមត្ថកិច្ច ដើម្បីគាំទ្រដល់ការរៀបចំលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ។

ក្រសួង ស្ថាប័នមានសមត្ថកិច្ចទាំងអស់ត្រូវគាំទ្រដល់តំណាងសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ។

តំណាងសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវប្រើប្រាស់យោបល់បច្ចេកទេសដែលបានមកពីដៃគូបច្ចេកទេស និងអ្នកពាក់ព័ន្ធដែលមានការចាប់អារម្មណ៍ ដើម្បីរៀបចំលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ។ តួនាទីជាក់លាក់សម្រាប់ដៃគូបច្ចេកទេសពាក់ព័ន្ធ អាចដាក់បញ្ចូលនៅក្នុងលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ។

**មតិយោបល់** ៖តើលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នាមានជាគោលការណ៍ណែនាំ ឬក៏សេចក្តីនៃណាំ? ពេលណាទើបមាន?

**មាត្រា៣១៩**._ ការពិនិត្យលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា

នៅពេលតំណាងសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច រដ្ឋបាលថ្នាក់ក្រោមជាតិ បានបំពេញតាមលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា តំណាងសហគមន៍មូលដ្ឋាន ជនជាតិដើមភាគតិច រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវដាក់សំណើដោយភ្ជាប់លក្ខខណ្ឌទាំងនេះទៅក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ដើម្បីបង្កើតការគ្រប់គ្រងរួមគ្នា ។

ក្រសួង ស្ថាប័នទទួលបរិស្ថាន ត្រូវពិនិត្យ និងផ្តល់យោបល់លើលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ស្របតាមលក្ខណៈវិនិច្ឆ័យ និងនីតិវិធី ក្នុងរយៈពេលបីខែ បន្ទាប់ពីទទួលបានសំណើសុំរៀបចំការគ្រប់គ្រងរួមគ្នា ។

មតិយោបល់ទាំងនេះ រួមមាន ៖

១- សេចក្តីសម្រេច ដើម្បីផ្តួចផ្តើមគំនិតក្នុងការគ្រប់គ្រងរួមគ្នាក្នុងតំបន់ស្នើសុំ ។

២- សេចក្តីសម្រេច ដើម្បីផ្តួចផ្តើមគំនិតក្នុងការគ្រប់គ្រងរួមគ្នា នៅក្នុងតំបន់ស្នើសុំ បន្ទាប់ពីបានដាក់បញ្ចូលមតិយោបល់របស់ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថានទៅក្នុងលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នានោះ ឬ

៣- សេចក្តីណែនាំ ដើម្បីកែសម្រួលលើលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ក្នុងការដាក់សំណើសុំពិនិត្យ និងផ្តល់យោបល់សាជាថ្មី ។

ក្នុងករណីមានការដាក់សំណើស្នើសុំពិនិត្យ និងផ្តល់យោបល់សាជាថ្មី ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ត្រូវពិនិត្យលើលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នាដែលបានកែសម្រួល ក្នុងរយៈពេលបីខែបន្ទាប់ពីបានទទួលសំណើស្នើសុំនេះ ។

ឯកសារទាំងអស់ដែលទាក់ទងនឹងលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា ត្រូវដាក់ឱ្យសាធារណៈជនអាចស្វែងបាន ។

**មតិយោបល់** ៖នៅតែមិនការបញ្ជាក់ឲ្យបានច្បាស់លាស់ពី ពីក្រសួងដែលត្រូវដាក់ការស្នើរសុំ។

ក្នុងករណីដែលមិនមានការឆ្លើយតបក្នុងរយៈ ៣ខែ ពីក្រសួង គួរត្រូវបានទទួលស្គាល់នូវលក្ខខណ្ឌនៃការគ្រប់គ្រងរួមគ្នា។

**មាត្រា៣២០**._ លិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងរួមគ្នា

| |
|---|
| ក្រសួង ស្ថាប័នទទួលបរិស្ថាន ត្រូវរៀបចំសំណើស្នើសុំបង្កើតការគ្រប់គ្រងរួមគ្នា ទៅកាន់រាជរដ្ឋាភិបាល ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីមានការផ្តួចផ្តើមគំនិតឱ្យមានការគ្រប់គ្រងរួមគ្នា ។<br>ក្រោយពីទទួលបានសំណើស្នើសុំបង្កើតការគ្រប់គ្រងរួមគ្នា រាជរដ្ឋាភិបាល ត្រូវចេញលិខិតបទដ្ឋានគតិយុត្ត ដូចខាងក្រោម ៖<br>១- បង្កើតអាជ្ញាធរគ្រប់គ្រងរួមគ្នា ជានីតិបុគ្គលសាធារណៈ ។<br>២- កំណត់ពីភារកិច្ច និងតួនាទីរបស់អាជ្ញាធរគ្រប់គ្រងរួមគ្នា រួមមានសិទ្ធិគ្រប់គ្រងមូលនិធិ ចុះកិច្ចព្រមព្រៀង ធ្វើប្រតិបត្តិការ និងបង្កើតប្រាក់ចំណូល និងចុះបញ្ជីដីធ្លីជាមួយរដ្ឋបាលសុរិយោដី ក្នុងនាមជាអាជ្ញាធរកាន់កាប់ដីរដ្ឋនៅក្នុងតំបន់គ្រប់គ្រងរួមគ្នា ។<br>៣- ទទួលស្គាល់តំបន់គ្រប់គ្រងរួមគ្នា ។<br>រាល់ការចុះកិច្ចព្រមព្រៀង ឬការផ្តល់ការធ្វើប្រតិបត្តិការផ្នែកពាណិជ្ជកម្ម ដែលអនុញ្ញាត ទៅឱ្យអ្នករស់នៅក្រៅតំបន់គ្រប់គ្រងរួមគ្នា ចេញចូលតំបន់គ្រប់គ្រងរួមគ្នា ក្នុងការធ្វើអាជីវកម្មលើធនធានធម្មជាតិ ត្រូវទទួលការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន ។<br>អាណត្តិនៃអាជ្ញាធរគ្រប់គ្រងរួមគ្នាមានរយៈពេលមិនកំណត់ ។<br><br>**មតិយោបល់** ៖នៅពេលដែលមានសំណើរមកកាន់ស្ថានប័នជំនាញ ក្នុងរយៈពេល៣ខែ ស្ថាប័នជំនាញត្រូវដាក់សំណើរទៅកាន់រាជរដ្ឋាភិបាល (តើនណាជាតំណាងឲ្យរាជរដ្ឋាភិបាលក្នុងអនុម័តគម្រោសំណើរនេះ) ដូចនេះនណារនឹងធ្វើការតាមដានលើសំណើរសុំនេះ?<br>ការបង្កើតអាជ្ញាធរគ្រប់គ្រងរួមគ្នា ជានីតិបុគ្គលសាធារណៈ ។ តើតំណាងសហគមន៍ត្រូវមានវត្តមាននៅក្នុងអាជ្ញាធរគ្រប់គ្រងរួមគ្នា ជានីតិបុគ្គលសាធារណៈ ។ដោយសារនៅក្នុងមាត្រា ៣១៧ តម្រូវឲ្យមានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងរួមគ្នា ដូចនេះសមាសភាព នេះគួរត្រូវបានបញ្ចូលទៅក្នុងអាជ្ញាធរគ្រប់គ្រងរួមគ្នា។<br>ចំណុចនេះគួរលុបចោល ឬបន្ថែមថា រាល់ការចុះកិច្ចព្រមព្រៀង ឬការផ្តល់ការធ្វើប្រតិបត្តិការផ្នែកពាណិជ្ជកម្ម ដែលអនុញ្ញាត ទៅឱ្យអ្នករស់នៅក្រៅតំបន់គ្រប់គ្រងរួមគ្នា ចេញចូលតំបន់គ្រប់គ្រងរួមគ្នា ក្នុងការធ្វើអាជីវកម្មលើធនធានធម្មជាតិ ត្រូវទទួលការអនុញ្ញាតពីក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន **និងដោយមានការឯពីអាជ្ញាធរគ្រប់គ្រងរួមគ្នា**។ |
| **សំណូមពរ៖** |

**មាត្រា៣២១** ._ កិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន និងអាជ្ញាធរគ្រប់គ្រងរួមគ្នា ត្រូវចុះកិច្ចព្រមព្រៀងគ្រប់គ្រងជាមួយគណៈកម្មការគ្រប់គ្រងរួមគ្នា ក្នុងរយៈពេល ៣ (បី) ខែ បន្ទាប់ពីរាជរដ្ឋាភិបាលបានផ្តល់ការឯកភាពលើការគ្រប់គ្រងរួមគ្នា ។

**មាត្រា៣៣១**ការរៀបចំសមាសភាគនៃប្រព័ន្ធតំបន់ការពារធម្មជាតិ

មាត្រានេះគួរត្រូវបានដាក់បញ្ចូលទៅក្នុងមានតិការទី១ **មាតិកាទី១៖ប្រព័ន្ធតំបន់ការពារធម្មជាតិ ជំពូកទី១៖ការរៀបចំប្រព័ន្ធតំបន់ការពារធម្មជាតិ**

**សំណូមពរ៖**

**មាត្រា៣២៥** ._ ការលុបចោលកិច្ចព្រមព្រៀងស្តីការគ្រប់គ្រងរួមគ្នា និងការរំលាយអាជ្ញាធរគ្រប់គ្រងរួមគ្នា

ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន មានសិទ្ធិលប់ចោលកិច្ចព្រមព្រៀងស្តីពីការគ្រប់គ្រងរួមគ្នា ឬតំបន់គ្រប់គ្រងរួមគ្នា ក្នុងករណីដូចខាងក្រោម ៖

១- មានការបំពានធ្ងន់ធ្ងរលើកិច្ចព្រមព្រៀងគ្រប់គ្រងរួមគ្នា ។

២- មានការបំពានច្បាប់ធ្ងន់ធ្ងរ នៅក្នុងការអនុវត្តការគ្រប់គ្រងរួមគ្នា ។

ក្នុងករណីដែលមានការលុបចោលកិច្ចព្រមព្រៀងរួមគ្នា ឬតំបន់គ្រប់គ្រងរួមគ្នា ក្រសួង ស្ថាប័នទទួលបន្ទុកបរិស្ថាន មានសិទ្ធិស្នើសុំឱ្យរាជរដ្ឋាភិបាលរំលាយអាជ្ញាធរគ្រប់គ្រងរួមគ្នា ។

មុនពេលចេញសេចក្តីសម្រេចលុបចោលកិច្ចព្រមព្រៀងស្តីការគ្រប់គ្រងរួមគ្នា ឬតំបន់គ្រប់គ្រងរួមគ្នា និងការរំលាយអាជ្ញាធរគ្រប់គ្រងរួមគ្នា ភាគីពាក់ព័ន្ធទាំងអស់ត្រូវជួបគ្នាដើម្បីពិភាក្សា និងស្វែងរកដំណោះស្រាយដោយសន្តិវិធីជាមុនសិន ។ ក្រោមការសម្របសម្រួលពីក្រសួង ស្ថានប័នទទួលបន្ទុកបរិស្ថាន

អាជ្ញាធរគ្រប់គ្រងរួមគ្នាដែលទទួលរងផលប៉ះពាល់ដោយសារការលុបចោលកិច្ចព្រមព្រៀងស្តីការគ្រប់គ្រងរួមគ្នា និងការរំលាយអាជ្ញាធរគ្រប់គ្រងរួមគ្នា មានសិទ្ធិធ្វើបណ្តឹងតវ៉ា ស្របតាមបទប្បញ្ញត្តិនៃក្រមនេះ ។

| |
|---|
